SPP
Translation & Interpretation

ច័ន្ទ ឫទ្ធី

# ស្វែងយល់

# ចង់ក្លាយជាអ្នកនិពន្ធ

ម្មការនិពន្ធ ជាវិជ្ជាដែលគ្មាននរណារៀនចប់

LC
802
CHA

NEAK MEAS PRINTING HOUSE
012/016 954 953

តម្លៃ ៥០០០រៀល

www.elibraryofcambodia.org

# ស្វែងយល់ចង់ក្លាយជាអ្នកនិពន្ធ

បោះពុម្ពលើកទី ១ ខែតុលា គ.ស ២០០៥

ចំនួន ២០០០ ក្បាល

ចំន្ទ ឫទ្ធី

ព្រះរាជាណាចក្រកម្ពុជា
0091/08
បណ្ណាល័យជាតិ

National Library of Cambodia
00012967

www.elibraryofcambodia.org

# អារម្ភកថា

ខ្ញុំសរសេរសៀវភៅ**ស្វែងយល់ចង់ក្លាយជាអ្នកនិពន្ធ**នេះ ដោយមានបំនងប្រមូលចងក្រងនូវអ្វីដែលខ្ញុំធ្លាប់ស្វែងយល់អំពីកិច្ចការនិពន្ធតាមរយៈការចូលរួមក្នុងសិក្ខាសាលាវគ្គបណ្តុះបណ្តាល និងការអានសៀវភៅជាភាសាបរទេស។ តាមពិតទៅខ្ញុំក៏ពុំទាន់ធ្លាប់បានសរសេររឿងប្រលោមលោកនៅឡើយទេ។ ប៉ុន្តែខ្ញុំយល់ថាបើខ្ញុំចាប់ផ្តើមសរសេររឿងមុននោះខ្ញុំអាចនឹងគ្មានឱកាសចែករំលែកនូវអ្វីដែលខ្ញុំធ្លាប់បានស្វែងយល់ដល់អ្នកដទៃឡើយ។

ខ្ញុំជឿថាមានអ្នកចង់ស្វែងយល់ពីកិច្ចការនិពន្ធជាច្រើនទៀតដែលពុំមានពេលវេលារឺពុំមានឱកាសបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្សេងៗ។ ហេតុនេះ ទើបខ្ញុំខិតខំរៀបរៀងសៀវភៅនេះ ទោះបីជារូបខ្ញុំពុំទាន់មានបទពិសោធក្តី ទោះបីជាខ្ញុំដឹងថាទីផ្សារចង្អៀតក្តីទោះបីជាមានអ្នករិះគន់ខ្ញុំក្តីក៏គ្មានអ្វីមករារាំងការតាំងចិត្តរបស់ខ្ញុំបានឡើយ។ ទីបំផុតការព្យាយាមរបស់ខ្ញុំបានមកដល់ទីបញ្ចប់ តែខ្ញុំប្រាកដក្នុងចិត្តថាពិតជាមានកង្វះខាតមិនខាន។ ផ្ទុយទៅវិញ បើខ្ញុំខ្លាចគេរិះគន់ ហើយមិនរៀបរៀងសៀវភៅនេះ នោះវិប្បដិសារីពិតជាជេរស្តីអោយខ្ញុំមិនខាន។ ទោះជាយ៉ាងណាក្តី ខ្ញុំបានខិតខំសិរិតសំរាំងអស់ពីកំលាំងកាយចិត្តនិងសតិបញ្ញាដែលមានទៅហើយ ពុំមានលាក់បាំងអ្វីបន្តិចណាឡើយ។

ខ្ញុំសង្ឃឹមថាក្រោយពីលោកអ្នកអានដែលមានបំនងចង់ក្លាយជាអ្នកនិពន្ធបានអានសៀវភៅនេះ ពិតជាអាចទទួលបាននូវការយល់ដឹងអំពីកិច្ចការនិពន្ធខ្លះៗ ហើយអាចយកទៅច្នៃប្រឌិតប្រើបាន ជាក់ជាពុំខានឡើយ។

ភ្នំពេញ ថ្ងៃទី ២៣ ខែតុលា ឆ្នាំ ២០០៥

**ចំន្ន ឫទ្ធី**

www.elibraryofcambodia.org

# សូមឧទ្ទិសស្នាដៃនេះជូន

លោកគ្រូ អ្នកគ្រូ ព្រះសង្ឃ សាស្ត្រាចារ្យជាតិនិងបរទេសទាំងអស់ ដែលធ្លាប់បានបង្ហាត់បង្រៀនខ្ញុំ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកនិពន្ធបរទេស ដែលធ្លាប់បានស្ម័គ្រចិត្តមកចែករំលែកបទពិសោធដល់ខ្ញុំនិងសិក្ខាកាមរួមជំនាន់។ ជាពិសេសកញ្ញា Arianne Cohen ។

www.elibraryofcambodia.org

# មាតិកា


សេចក្តីផ្តើម .......... ១

ស្វែងយល់ពីអ្នកអាន .......... ៤

សិល្បៈនៃការសរសេរប្រលោមលោក .......... ៦

ការបង្កើតគំនិត .......... ៧

ការផ្តើមរឿង .......... ១៤

តួអង្គ .......... ១៨

ការបង្កើតតួអង្គ .......... ២៤

គ្រោងរឿង .......... ៣៣

ការតំណាលតាមទស្សនៈ .......... ៤១

ការរៀបចំឆាក .......... ៤៦

ការបញ្ចប់រឿង .......... ៤៨

រឿងខ្លី រឿង រឿងថៅកែម៉ែផ្កាំ .......... ៥៣


www.elibraryofcambodia.org

# សេចក្តីផ្តើម

មនុស្សយើងតែងតែមានក្តីសុបិនចង់ធ្វើនេះ ចង់ធ្វើនោះ តែមានមនុស្សជាច្រើនដែលក្តីសុបិនរបស់គេមិនអាចក្លាយជាការពិតបាន ដោយសារតែហេតុផលផ្សេងៗពីគ្នា។ យ៉ាងណាមិញ ក្តីសុបិនចង់ក្លាយជាអ្នកនិពន្ធរបស់យើង ក៏វាមិនខុសគ្នានឹងក្តីសុបិនទាំងនោះដែរ។ ពោលគឺក្តីសុបិនចង់ក្លាយជាអ្នកនិពន្ធមិនអាចក្លាយជាការពិតបាន ភាគច្រើនស្ទើរតែមួយរយភាគរយ គឺបណ្តាលមកពីយើងមិនទាន់បានចាប់ផ្តើមសរសេររឿង ហើយអាចមានខ្លះដែរ ដែលបានចាប់ផ្តើមសរសេរហើយ តែឈប់ទៅវិញ ព្រោះគេមិនអាចសរសេរបន្តទៅទៀតបាន។ ម្យ៉ាងទៀតអាចមានមួយចំនួនដ៏តិចតួចទៀត ដែលសរសេរចប់ហើយ តែពុំមានលទ្ធភាពបោះពុម្ព។

ទោះជាយ៉ាងណាក្តី បើសិនយើងពិតជាស្រលាញ់កិច្ចការនិពន្ធ យើងពិតជាមានក្តីសុបិនចង់ក្លាយជាអ្នកនិពន្ធមែននោះ រាល់បញ្ហាទាំងនោះ ក៏ពិតជាអាចរកដំណោះស្រាយបានដោយខ្លួនយើងផ្ទាល់ ព្រោះគ្រប់បញ្ហា សុទ្ធតែមានមធ្យោបាយដោះស្រាយ មិនមែនគ្រប់មធ្យោបាយដោះស្រាយទាំងអស់សុទ្ធតែមានបញ្ហានោះទេ។ មានន័យថា យើងត្រូវតែមានជំនឿជាក់លើខ្លួនឯងជានិច្ច។

មួយវិញទៀត បើយើងពិតជាស្រលាញ់កិច្ចការនិពន្ធមែនហើយនោះ ថ្វីបើការនិពន្ធមិនមែនជាការងាយស្រួលក៏ពិតមែន តែវាក៏មិនលំបាកហួសក្តីប្រាថ្នារបស់យើងដែរ។ តាមការពិតទៅ អ្វីៗដែលទើបនឹងចាប់ផ្តើម វាតែងមានការលំបាកជាធម្មតា។ ដូចនេះយើងគួរតែរិះគិតរកមើលមធ្យោបាយ ដែលអាចនឹងជួយធ្វើអោយ

www.elibraryofcambodia.org

ក្តីសុបិនរបស់យើងក្លាយជាការពិតវិញ ទើបប្រសើរជាជាង ។

**មុនអ្វី១ទាំងអស់ យើងគួរសួរខ្លួនឯងថា យើងមានគោលបំនងអ្វី ហើយអ្វីដែលបណ្តាលចិត្តយើងអោយចង់ក្លាយជាអ្នកនិពន្ធ?**

អ្នកខ្លះចង់ក្លាយជាអ្នកនិពន្ធ ព្រោះគេចង់ល្បីឈ្មោះ ។ ប៉ុន្តែថ្វីបើការក្លាយជាអ្នកនិពន្ធអាចនឹងធ្វើអោយយើងមានកេរ្តិ៍ឈ្មោះបានក៏ពិតមែន តែវាក៏មិនសូវជាល្បីប៉ុន្មានទេ បើសិនយើងធ្វើការប្រៀបធៀបនឹងតារាភាពយន្តឬអ្នកចំរៀងនោះ ។ ដូចនេះ បើសិនណាអ្នកចង់មានឈ្មោះល្បីល្បាញដែលនរណាក៏ស្គាល់អ្នកដែរនោះ អ្នកមិនគួរនឹងជ្រើសរើសយកអាជីពជាអ្នកនិពន្ធឡើយ ។

អ្នកខ្លះចង់ក្លាយជាអ្នកនិពន្ធ ព្រោះគេចង់ក្លាយជាអ្នកមាន ។ ក្នុងប្រទេសកម្ពុជាយើងនេះ ឱកាសដែលនឹងក្លាយជាអ្នកមាន ដោយសារតែការនិពន្ធមានតិចណាស់ ឬគ្មានសោះតែម្តង ព្រោះបើយើងជាអ្នកនិពន្ធថ្មីចង់លក់ស្នាដៃ ក៏ពិបាកនឹងរកអ្នកទិញណាស់ ហើយទោះជាយើងមានឈ្មោះល្បីហើយក្តី ក៏អាចលក់ស្នាដៃបានក្នុងតំលៃថោកនៅឡើយដែរ ។

អ្នកខ្លះចង់ក្លាយជាអ្នកនិពន្ធ ព្រោះចង់មានមោទនភាពលើខ្លួនឯង ពេលស្នាដៃរបស់ខ្លួនត្រូវបានបោះពុម្ពផ្សព្វផ្សាយជាសាធារណៈ ។ ការទទួលអារម្មណ៍នេះក៏មានក្នុងអារម្មណ៍របស់អ្នកនិពន្ធទាំងឡាយផងដែរ ។

អ្នកខ្លះចង់ក្លាយជាអ្នកនិពន្ធ ព្រោះគេចង់រៀបរាប់រឿងដែលកើតមានពីការស្រមើស្រមៃ ពីចេតនារម្មណ៍របស់គេ អោយដល់អ្នកអាន ។

អ្នកខ្លះចង់ក្លាយជាអ្នកនិពន្ធ ព្រោះតែគេចង់សរសេរ តែគេមិនខ្វល់ខ្វាយ

www.elibraryofcambodia.org

ពីអ្វីសោះឡើយ ក្រៅពីការបានសរសេរពីអ្វីដែលគេអាចសរសេរបាន និងធ្វើបាន ល្អបំផុតអស់ពីសមត្ថភាព ហើយនេះគឺជាការពេញចិត្តរបស់គេ។

ទោះជាយ៉ាងណាអ្នកដែលចង់ក្លាយជាអ្នកនិពន្ធ ភាគច្រើនតែងមានបំនង ប្រាថ្នាចង់បានដូចរៀបរាប់ខាងលើនេះ លាយឡំផ្សំគ្នាទាំងអស់។ ប៉ុន្តែអាចមានការ នឹកគិត ការយល់ឃើញ និងមានការកំនត់កត្តាជោគជ័យផ្សេងពីគ្នា រឺមិនស្មើគ្នា។ អ្នកខ្លះយល់ថា ជោគជ័យស្ថិតលើការអាចទទួលបានប្រាក់ច្រើន ពីការសរសេររបស់ ខ្លួន។ ចំនែកឯអ្នកខ្លះទៀតយល់ថា ជោគជ័យស្ថិតលើការសរសេរចប់ ហើយអាច បោះពុម្ពផ្សព្វផ្សាយជាសាធារណៈបាន មានសៀវភៅដែលខ្លួនបានសរសេរបង្ហាញ អ្នកផងទាំងឡាយថា "**ឥឡូវនេះ ខ្ញុំអាចធ្វើបានហើយ!...**"។

ចំពោះខ្ញុំ (**ច័ន្ទ ឫទ្ធី**) ចង់ក្លាយជាអ្នកនិពន្ធ ព្រោះខ្ញុំចង់សរសេរ ហើយខ្ញុំមិន ខ្វល់ខ្វាយពីអ្វីផ្សេងទៀតឡើយ ក្រៅពីការសរសេរពីអ្វីដែលខ្ញុំអាចនឹងសរសេរបាន តាមការយល់ដឹងរបស់ខ្លួន។ ពោលគឺ ខ្ញុំចង់សរសេររៀបរាប់រឿងរ៉ាវដែលកើតមាន ក្នុងការនឹកគិតស្រមើស្រមៃអោយអ្នកអានបានអាន។ មានន័យថា ខ្ញុំប៉ងប្រាថ្នាចង់ អោយសំនេររបស់ខ្ញុំបានបោះពុម្ពផ្សព្វផ្សាយជាសាធារណៈ តែប៉ុណ្ណឹងខ្ញុំសប្បាយចិត្ត ណាស់ទៅហើយ!...

**ចុះអ្នកវិញ!...**

**តើអ្នកចង់ក្លាយជាអ្នកនិពន្ធ ដោយសារតែមូលហេតុអ្វីដែរ?**

www.elibraryofcambodia.org

# ស្វែងយល់ពីអ្នកអាន

**ប្រសិនបើយើងចង់ក្លាយជាអ្នកនិពន្ធ មុនអ្វីៗទាំងអស់យើងគួរស្វែងយល់ រឺត្រូវដឹងថា តើអ្នកអានអានរឿងប្រលោមលោកដើម្បីអ្វី?**

តាមការសង្កេតជាទូទៅឃើញថា មនុស្សយើងអានប្រលោមលោកដើម្បី

-កំសាន្តលេង

-បន្ធូរអារម្មណ៍តានតឹង

-យល់ដឹងពីទីកន្លែងនានា

-យល់ដឹងពីរបៀបទំនាក់ទំនង

-ទទួលបាននូវគំនិតថ្មីៗ

-ទទួលបាននូវបទពិសោធថ្មី

-សិក្សាស្វែងយល់ពីចំនេះដឹងទូទៅ

-យល់ដឹងពីបញ្ហាផ្សេងៗ...

**ឧទាហរណ៍** យើងនៅមិនទាន់រៀបការ ។ បើសិនយើងបានអានសៀវភៅ ប្រលោមលោករឺបានអានសៀវភៅផ្សេងៗស្តីពីជីវិតអាពាហ៍ពិពាហ៍នោះ ក៏នឹងធ្វើ អោយយើងអាចទទួលបាននូវចំនេះដឹងផ្សេងៗ ដែលទាក់ទងនឹងជីវិតអាពាហពិពាហ៍ ដូចជា យល់ដឹងពីកំហុសឆ្គងផ្សេងៗក្នុងឆាកជីវិតគូស្វាមីភរិយា ដឹងពីគូជីវិត ដែលមិនបានសមតាមបំនងតាមរយៈតួអង្គក្នុងរឿង ហើយរិះគិតថា តើយើងត្រូវ

www.elibraryofcambodia.org

ធ្វើយ៉ាងដូចម្ដេចដើម្បីការពារមិនអោយដំនើរជីវិតរបស់យើងដូចរឿងទាំងនោះ? តើយើងគួរធ្វើដូចម្ដេច ទើបអាចធ្វើអោយជីវិតយើងល្អប្រសើរជាងតួអង្គក្នុងរឿងទាំងនោះ?

បើយើងបានរិះគិតដូចខាងលើនេះបន្ទាប់ពីអានរឿងប្រលោមលោក នោះយើងក៏អាចទទួលបាននូវចំនេះដឹងពីរឿងប្រលោមលោក ។ ម្យ៉ាងវិញទៀតការអានរឿងប្រលោមលោក ងាយស្រួលចងចាំជាងអានសៀវភៅអប់រំ ដែលមានសុទ្ធតែវិធីសាស្ត្រសំខាន់ៗ ព្រោះប្រលោមលោកមានទាំងដំនើររឿង ដែលមានបង្កប់ការអប់រំតាមសិល្បវិធីរបស់អ្នកនិពន្ធផង ដែលធ្វើអោយអ្នកអានអាចចងចាំបានយូរ ។

សរុបមក ការអានប្រលោមលោកមានគោលបំនងធំៗពីរ គឺអានដើម្បីមានអារម្មណ៍ស្រមើស្រមៃ និងអានដើម្បីសិក្សាស្វែងយល់ ។

**សំនួរ-** ហេតុអ្វីបានជាពេលខ្លះ យើងអានសៀវភៅរហូតដល់ជក់ចិត្តជិតអារម្មណ៍មិនចង់ដាក់សៀវភៅចុះពីដៃ?

**ចំលើយ-** គឺមកពីយើងជឿជាក់លើការស្រមើស្រមៃដោយបានអានពាក្យរបស់អ្នកនិពន្ធ ហើយពាក្យទាំងនោះអាចទាក់ទាញអារម្មណ៍របស់យើងបាន ។

**សំនួរ-** តើហេតុអ្វីបានជាមនុស្សយើងចូលចិត្តជឿមនុស្សដែលប៉ិនកុហក?

**ចំលើយ-** ព្រោះមនុស្សដែលពូកែកុហកប្រសប់រៀបរាប់យ៉ាងល់អិត ។

**ដូចនេះការបង្កើតការស្រមើស្រមៃដែលល្អ ត្រូវមានភាពជាក់លាក់រូបិយ និងមានភាពល់អិតផង ។**

www.elibraryofcambodia.org

# សិល្បៈនៃការសរសេរប្រលោមលោក

ក្នុងការនិពន្ធរឿងមិនមានក្បួនច្បាប់ណាមួយជាក់លាក់នោះទេ អាស្រ័យលើអ្នកនិពន្ធម្នាក់ៗ ចង់សរសេរ រឺមានចំនូលចិត្ត ។ ម្យ៉ាងទៀតរឿងដែលល្អបំផុតក៏មិនមែនមានវិធីសរសេរតែមួយបែបនោះដែរ ។ ប៉ុន្តែអ្វីដែលសំខាន់នោះ គឺអ្នកនិពន្ធត្រូវចេះបង្កើតទំនាស់ ចេះស្រាយបញ្ហាបញ្ចប់រឿងយ៉ាងណា បំផុសអោយអ្នកអានបញ្ចេញទស្សនៈផ្សេងៗគ្នា លើផ្ទៃរឿងរបស់ខ្លួន ក្រោយពីគេបានអានចប់ ។

ការនិពន្ធប្រលោមលោក ជាវិធីធ្វើអោយមានការស្រមើស្រមៃដោយប្រើពាក្យពេចន៍រៀបរៀង ។ ដូចនេះ**ពាក្យពេចន៍** ជា**ឧបករណ៍ដ៏សំខាន់**របស់**អ្នកនិពន្ធ**។ ហេតុនេះការជ្រើសរើសប្រើពាក្យ និងការរៀងលំដាប់ពាក្យមានសារៈសំខាន់ខ្លាំងណាស់ ក្នុងកិច្ចការនិពន្ធរឿងរបស់យើង ។

ការសរសេររឿងប្រលោមលោក គឺជាវិធីដែលមិនអាចនឹងនិយាយបានថាអាចបង្រៀនបាននោះទេ ។ ប៉ុន្តែគ្រាន់តែអាចណែនាំបានខ្លះៗ បើសិនណាជាយើងចង់រៀន ។ ការរៀនសរសេររឿងប្រលោមលោកដែលល្អបំផុត គឺការព្យាយាមអានប្រលោមលោក ហើយចេះសន្សំពាក្យពេចន៍ សន្សំល្បះល្អៗ ពិនិត្យសង្កេតសិល្បវិធីសរសេររបស់អ្នកនិពន្ធជំនាន់មុន រួចហើយខិតខំរៀនសរសេរដោយខ្លួនឯង ។ **ពោល**

www.elibraryofcambodia.org

## ការបង្កើតគំនិត

ប្រលោមលោកកើតចេញពីការបង្កើតអោយមានរូបភាពនៅក្នុងអារម្មណ៍របស់អ្នកនិពន្ធ ដែលក្នុងនោះមានទាំងចំនេះដឹងពិត( បទពិសោធជីវិត )និងចំនេះដឹងមិនពិត( ការស្រមើស្រមៃ )រួមបញ្ចូលគ្នា។ ដូចនេះរឿងប្រលោមលោកជាការនិម្មិតរបស់អ្នកនិពន្ធ ដែលករណីខ្លះអ្នកនិពន្ធអាចយកលំនាំតាមបទពិសោធជីវិតមួយភាគធំច្របល់ចូលគ្នានឹងការស្រមើស្រមៃ រឺមួយក៏យកលំនាំតាមការស្រមើស្រមៃមួយភាគធំច្របល់ចូលគ្នានឹងបទពិសោធជីវិត ហើយក៏សរសេរតាមកំរិតចំនេះដឹងរបស់ខ្លួន បង្កើតបានជាប្រលោមលោកដែលល្អមើល គួរអោយចង់តាមដាន។

**ការបង្កើតគំនិតអាចបានមកពី :**

**-បទពិសោធជីវិត**

**-ការស្រមើស្រមៃ**

**-ការអាន ការគិត ការស្តាប់និងការមើលបែបអ្នកនិពន្ធ**

**១-ការបង្កើតគំនិតសរសេររឿងតាមរយៈបទពិសោធជីវិត**

**ក-ការបង្កើតគំនិតសរសេររឿងតាមរយៈបទពិសោធជីវិតរបស់ខ្លួនឯង**

មនុស្សគ្រប់រូបមានបទពិសោធជីវិតមិនដូចគ្នាទេ។ បើសិនជីវិតរបស់យើងពោរពេញទៅដោយបទពិសោធប្លែកៗថ្មីៗ នោះយើងមិនបាច់ស្វះស្វែងរករឿងរ៉ាវផ្សេងទៀតក៏បានដែរ។ ចំនុចល្អនៃការសរសេររឿងផ្ទាល់ខ្លួនឯង គឺយើងអាចនឹងសរសេរបានត្រូវតាមបទពិសោធជីវិតដែលយើងបានដឹងពិត ពុំមាននរណាអាចដឹងដូចយើង ឬដឹងស្មើនឹងយើងបានទេ។ ប៉ុន្តែរឿងប្រលោមលោកនឹងជីវិតពិត វាខុសប្លែកពីគ្នា

www.elibraryofcambodia.org

ពេលយើងលើកយកប្រវត្តិជីវិតពិតមកសរសេរជាប្រលោមលោកនោះ យើងត្រូវបញ្ចូលគំនិតស្រមើស្រមៃរួមផ្សំជាមួយផង ដោយមិនអាចចៀសវាងបានឡើយ។

ដូចនេះ ដើម្បីអោយយើងអាចនឹងបង្កើតគំនិតសរសេររឿងបាន យើងត្រូវតែរ៉ឺកហាត់សរសេររឿងរ៉ាវរបស់ខ្លួនឯង មានដូចជា ៖

-កត់ត្រាព័ត៌មានសំខាន់ៗប្រចាំថ្ងៃរបស់ខ្លួនឯង

-សរសេរពីអ្វីដែលសំខាន់របស់ជីវិតខ្លួនឯងដែលបានជួបប្រទះ

-សរសេរពីអនុស្សាវរីយ៍ទាំងឡាយដែលខ្លួនយើងធ្លាប់មាន

-សរសេរដោយសេរីអំពីទេសភាព រឿងរ៉ាវ រឺអ្វីៗដែលយើងបានឃើញបានជួបប្រទះ រឺបានស្តាប់លឺ

វិធីខាងលើនេះ អាចនឹងជួយអោយយើងបង្កើតគំនិតក្នុងការសរសេររឿងបានឆាប់ ព្រោះវាជាលំហាត់ដែលយើងងាយនឹងធ្វើបាន។

## ខ-ការបង្កើតគំនិតសរសេររឿងតាមរយៈបទពិសោធជីវិតរបស់អ្នកដទៃ

ក្នុងការសរសេរប្រលោមលោកតាមបទពិសោធជីវិត យើងមិនមែនកំនត់យកតែបទពិសោធរបស់ខ្លួនឯងតែប៉ុណ្ណោះទេ គឺយើងអាចលើកយកបទពិសោធរបស់អ្នកដទៃមកធ្វើជាទិន្នន័យរឺធ្វើជាគំនិតសំរាប់សរសេរផងដែរ។ ប៉ុន្តែយើងគួរប្តូរឈ្មោះបុគ្គលពិត និងប្តូរឈ្មោះទីកន្លែងពិត ដើម្បីនឹងការពារការប្តឹងផ្តល់ពីម្ចាស់ប្រវត្តិជីវិតរឺទាយាទ ពេលណាដែលគេមានការអាក់អន់ចិត្ត។ ទោះជាយ៉ាងណាក្តីយើងក៏មិនអាចដឹងរឿងពិតរបស់អ្នកដទៃបានទាំងអស់ដែរ។ ដូចនេះយើងត្រូវចេះថែមថយសាច់រឿងខ្លះៗ តាមការស្រមើស្រមៃរបស់យើងផងទើបល្អ។

## ២-ការបង្កើតគំនិតសរសេររឿងតាមរយៈការស្រមើស្រមៃ

អ្នកនិពន្ធម្នាក់ៗតែងមានគំនិតក្នុងការនិពន្ធរឿងផ្សេងៗគ្នា។ អ្នកខ្លះអាច

www.elibraryofcambodia.org

សរសេររឿងបាន លុះណាតែគេបានដឹងរឿងនោះជាមុនសិនរីសរសេរតាមរឿងពិតប្រឌិតផ្សំ។ រីឯអ្នកខ្លះទៀត គេអាចសរសេររឿងបានតាមការស្រមើស្រមៃរីតាមការប្រឌិតរបស់គេផ្ទាល់តែម្តង។

រឿងពិតវាចាប់ផ្តើមពី ក-ខ-គ-ឃ-ង...រៀងតាមលំដាប់នៃដំណើររឿង។ ចំនែកឯរឿងប្រឌិតអាចចាប់ផ្តើមពី ក-ឃ-ង-គ-ខ...គឺលំដាប់រឿងអាចឆ្លាស់គ្នាមិនរៀងគ្នាតាមដំណើររឿងពិតនោះទេ។ ពោលគឺអាស្រ័យលើការសំរេចចិត្តរបស់អ្នកនិពន្ធម្នាក់ៗ។

**មធ្យោបាយក្នុងការបង្កើតការស្រមើស្រមៃមាន ៣ គឺ**

ក-យើងត្រូវធ្វើការនឹកគិតរកនិងសង្កេតតួអង្គ(តួអង្គអាចជាមនុស្សណាម្នាក់ដែលយើងបានជ្រើសរើសរឺកំនត់យក)ដោយសង្កេតពិនិត្យពីរបៀបរបបរស់នៅបុគ្គលិកលក្ខណៈ ទំលាប់...ហើយកត់ត្រាចូលទុកក្នុងសៀវភៅកំណត់ហេតុសំរាប់សរសេររឿងរបស់យើង។

ខ-យើងត្រូវរិះគិតបង្កើតប្រវត្តិជីវិតរបស់តួអង្គតាមការស្រមើស្រមៃរបស់យើង ហើយរៀបចំធ្វើតារាងប្រវត្តិរូបសង្ខេបរបស់តួអង្គ។ បន្ទាប់មកយើងជាអ្នកបំពេញជំនួសតួអង្គនោះ ដោយសន្មត់ថារូបយើងគឺជាតួអង្គនោះៗ។ ការធ្វើដូចនេះក្នុងបំណងដើម្បីអោយយើងបានស្គាល់តួអង្គកាន់តែច្បាស់ឡើង ហើយក៏អាចដឹងបានថា តួអង្គនោះៗ គេនឹងធ្វើយ៉ាងដូចម្តេច គេនឹងសំរេចចិត្តយ៉ាងណា គេនឹងដោះស្រាយបញ្ហាបែបណា នៅពេលណាគេបានជួបនឹងហេតុការណ៍ណាមួយបានជួបនឹងបញ្ហាចំពោះមុខ រីមានទំនាស់អ្វីកើតឡើង។

www.elibraryofcambodia.org

# ប្រវត្តិរូបសង្ខេបរបស់តួអង្គ

តួអង្គឈ្មោះ.................................ភេទ...................អាយុ...............

ទីកន្លែងកំណើត...............................................................................

ឪពុកឈ្មោះ...................................មុខរបរ.......................................

ម្តាយឈ្មោះ...................................មុខរបរ.......................................

ស្ថានភាពគ្រួសារពីកំណើត...............................................................

ចំរើនវ័យឡើងនៅទីណា ស្ថានភាពគ្រួសារយ៉ាងណា.................................

...........................................................................................................

ការិតវប្បធម៌.................................................................................

ប្រវត្តិការសិក្សា..............................................................................

...........................................................................................................

ចំនុចខ្លាំង.......................................................................................

ចំនុចខ្សោយ.....................................................................................

សុខភាពផ្លូវកាយ..............................................................................

សុខភាពផ្លូវចិត្ត................................................................................

សមត្ថភាពពិសេស..............................................................................

ពេលទំនេរចូលចិត្ត..........................................................................

មានទំនាស់អ្វី....................................................................................

..........................................................................ជាមួយនរណា...................

www.elibraryofcambodia.org

បងប្អូនឈ្មោះ..................អាយុ..............ភេទ...........កិរិតវប្បធម៌..........

ស្ថានភាពគ្រួសារ.........................................................................

ចំនុចខ្លាំង.................................................................................

ចំនុចខ្សោយ..............................................................................

មិត្តជិតស្និទ្ធឈ្មោះ................អាយុ.............កិរិតវប្បធម៌........................

ស្ថានភាពគ្រួសារ.........................................................................

ចំនុចខ្លាំង.................................................................................

ចំនុចខ្សោយ..............................................................................

ប្ដីប្រពន្ធ រឺសង្សារឈ្មោះ.....................អាយុ.............កិរិតវប្បធម៌..........

ស្ថានភាពគ្រួសារ.........................................................................

ចំនុចខ្លាំង.................................................................................

ចំនុចខ្សោយ..............................................................................

ពេលយើងស្រមើស្រមៃឃើញតួអង្គមានទំលាប់ធ្វើអ្វីខ្លះ នឹងដឹងពីប្រវត្តិជីវិតរបស់តួអង្គ ក៏នឹងធ្វើអោយយើងចាប់ផ្ដើមមានគំនិតសរសេររឿង ហើយក៏អាចពង្រីកផ្ទៃរឿងអោយធំទៅៗ រហូតដល់ក្លាយជារឿងមួយបាន។

គ-យើងរៀបចំសាកល្បងដាក់ចំណោទបញ្ហាផ្សេងៗអោយដល់តួអង្គ នៅទីកន្លែងផ្សេងពីគ្នា និងមានទំនាស់ផ្សេងពីគ្នា។

**៣-ការអាន ការគិត ការស្ដាប់ និងការមើលបែបអ្នកនិពន្ធ**

www.elibraryofcambodia.org

**អានបែបអ្នកនិពន្ធ** បើយើងចង់ក្លាយជាអ្នកនិពន្ធ ពេលយើងអានត្រូវតែមានការសង្កេតពីវិធីសរសេររឿងរបស់អ្នកនិពន្ធនោះ រួមជាមួយនឹងការអានផង។ ពេលនោះ យើងអាចនឹងសង្កេតមើលឃើញពីវិធីតំណាលរឿងរបស់អ្នកនិពន្ធនោះៗ និងអាចដឹងថា រឿងនោះអាចទាក់ទាញយើងអោយចូលជ្រៅទៅក្នុងដំនើររឿងបានដោយសារអ្វី អាចធ្វើអោយយើងជឿថាហេតុការណ៍នោះកើតឡើងពិតមែនរឺយ៉ាងណាទៅវិញ។

បើសិនយើងចង់សរសេរប្រលោមលោក យើងត្រូវតែអានប្រលោមលោក ហើយបើកាន់តែអានបានច្រើនប៉ុនណា ក៏កាន់តែមានប្រយោជន៍សំរាប់យើងច្រើនប៉ុននោះដែរ។ ពេលណាយើងបានអានរឿងច្រើនហើយនោះ វាមិនគ្រាន់តែអាចធ្វើអោយយើងអាចស្រាវជ្រាវរកឃើញថា វិធីសរសេរនិងវិធីតំណាលរឿងបែបណាដែលធ្វើអោយយើងពេញចិត្តប៉ុណ្ណោះទេ ថែមទាំងអាចធ្វើអោយយើងដឹងបានថាវិធីសរសេរនិងវិធីតំណាលរឿងបែបណា ដែលយើងមិនគួរធ្វើទៀតផង។

ប្រលោមលោកដែលល្អ គឺជាប្រលោមលោកដែលធ្វើអោយអ្នកអានកើតមានអារម្មណ៍ព្រមជាមួយនឹងតួអង្គ(ចូលតួ) ក្នុងពេលអាន។

**គិតបែបអ្នកនិពន្ធ** ការចាប់ផ្តើមគិតបែបអ្នកនិពន្ធអាចជួបនឹងការលំបាកខ្លះដែរ ព្រោះតាមធម្មតាមនុស្សយើងតែងគិតក្នុងកិរតមូល ដែលពុំចាំបាច់នាំយកការគិតនោះ មកសរសេរឡើងវិញទេ។ ម្យ៉ាងទៀតតាមធម្មតាមនុស្សយើងតែងប្រើវិញ្ញាណទាំង ៥ គឺចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ និងកាយវិញ្ញាណ ក្នុងការទទួលដឹងនូវអារម្មណ៍គ្រប់បែបយ៉ាង តែពេលគិត យើងប្រើ

www.elibraryofcambodia.org

ខួរក្បាល ។ ដូចនេះបើយើងចាប់ផ្តើមគិតបែបអ្នកនិពន្ធ យើងត្រូវប្រើខួរក្បាលនិងចិត្ត គិតទៅព្រមជាមួយគ្នាតែម្តង ។

ការពន្យល់ដូចខាងលើនេះ អាចនឹងពិបាកយល់បន្តិចដែរ ។ ប៉ុន្តែពេលដែលយើងចាប់ផ្តើមសរសេរ យើងនឹងដឹងខ្លួនថា ការគិតរបស់យើងចាប់ផ្តើមល់អិត និងស៊ីជំរៅជាងពេលមុន ។ ទាំងនេះអាចបណ្តាលមកពីមនសិការ ដែលមកជួយ រៀបចំពាក្យពេចន៍ រៀបចំល្បះ រៀបចំកថាខណ្ឌ និងរៀបចំដំណាក់កាលក្នុងការដំណាលរឿងបែបអ្នកនិពន្ធអោយដល់រូបយើង ដូចជា យើងនឹងដឹងថាបើយើងសរសេរត្រឹមតែពាក្យថា "នាងញញឹម" នោះមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ យើងត្រូវតែយល់ពីអត្ថន័យរបស់ការញញឹមនោះ ថាតើនាងញញឹមក្នុងលក្ខណៈបែបណា ការញញឹមនោះបង្កប់ រឺបង្ហាញអារម្មណ៍យ៉ាងដូចម្តេចផង ។

ការគិតបែបអ្នកនិពន្ធជាធ្វើដ៏សំខាន់ ដែលអាចនឹងនាំយើងឆ្ពោះទៅកាន់ការសរសេរបែបអ្នកនិពន្ធ ។

**ការស្តាប់និងការមើលបែបអ្នកនិពន្ធ** ពេលណាយើងបានលឺ រឺបានប្រទះឃើញរឿងរ៉ាវអ្វីមួយ ហើយចងចាំចំនុចដែលយើងពេញចិត្ត នោះយើងក៏អាចសន្សំការទទួលអារម្មណ៍នោះទុកក្នុងចិត្តរបស់យើង ។ លុះដល់ថ្ងៃណាមួយ យើងអាចនឹងយកមកដាក់ក្នុងរឿងដែលយើងសរសេរ បានខ្លះៗដែរ ។ ទាំងនេះមិនមែនមានន័យថា យើងមានការចងចាំច្រើនជាងអ្នកដទៃនោះទេ ។ ប៉ុន្តែវាមានន័យថា អ្នកដែលស្តាប់និងមើលបែបអ្នកនិពន្ធមានការចងចាំដែលស៊ីជំរៅជាង ហើយអាចនឹងយកចេញមកសរសេររៀបរាប់បាន ដោយប្រើវាជាចំនែកមួយក្នុងការសរសេររឿង ។

www.elibraryofcambodia.org

# ការផ្ដើមរឿង

អ្នកនិពន្ធតែងមានអាថិកំបាំងដូចគ្នា គឺថាមិនមាននរណាដឹងពិតប្រាដកថា ត្រូវផ្ដើមរឿងយ៉ាងដូចម្ដេចទេ ព្រោះកិច្ចការនិពន្ធពុំមានរូបមន្ដរឹក្សនខ្ចាតណាមួយជាក់លាក់ឡើយ ។ ម្យ៉ាងវិញទៀតប្រលោមលោកមួយរឿងៗ ក៏ជាពិភពមួយទៀតរបស់អ្នកនិពន្ធរូបនោះតែប៉ុណ្ណោះ ។

ចំនែកឯអ្នកនិពន្ធថ្មីវិញ គេច្រើនតែគិតថាការសរសេរល្បះដំបូង កថាខណ្ឌដំបូង វគ្គដំបូងនោះ វាមានការលំបាកណាស់ ព្រោះតែគេមានកង្វល់នឹងពាក្យថា **"ចាប់ផ្ដើមរឿង"** ទើបធ្វើអោយគេភ្លេចគិតថា ពេលចាប់ផ្ដើមរឿងវាមិនទាន់មានហេតុការណ៍សំខាន់ៗ ដែលជំរុញអោយកើតមានបញ្ហា កើតមានទំនាស់ រឺក៏កើតមានភាពស្មុគស្មាញរបស់តួអង្គនៅឡើយទេ ។

យើងអាចដឹងហើយថា សម័យបច្ចុប្បន្ននេះ មានទូរទស្សន៍ មានកុំព្យូទ័រ មានទូរស័ព្ទច្រើនសន្ធឹក... ជាហេតុធ្វើអោយអ្នកអានប្រលោមលោកមិនមានពេលវេលាច្រើនសំរាប់អានសៀវភៅរឿងប្រលោមលោក ដូចកាលពីសម័យមុនទៀតឡើយ ។ ដូចនេះយើងមិនគួរសរសេររៀបរាប់ហួរហែច្រើនហួសពេកទេ នៅក្នុងវគ្គដំបូងនេះ ។

## មធ្យោបាយក្នុងការសរសេរផ្ដើមរឿង

យើងគួរសាកល្បងបើកសៀវភៅប្រលោមលោកដែលយើងមាន រឺមួយក៏

www.elibraryofcambodia.org

ទៅបើកមើលនៅឯបណ្ណាគារ រឺបណ្ណាល័យក៏បាន ។ បន្ទាប់មកយើងអានឈ្មោះដំបូង អានកថាខណ្ឌដំបូង ហើយអានរហូតដល់ចប់វគ្គដំបូង ។ ពេលនោះយើងអាចនឹងដឹងបានថា ថាមពលនៃពាក្យ ដែលអ្នកនិពន្ធម្នាក់ៗបានយកមកដាក់រៀងគ្នាជាឈ្មោះ ជាកថាខណ្ឌ ជាវគ្គ វាអាចប្រែក្លាយជាអន្ទាក់ទាក់ទាញចំណាប់អារម្មណ៍របស់អ្នកអានបាន ហើយធ្វើអោយអ្នកអានចង់ដឹង និងចង់តាមដានរឿង ។ ដូចនេះយើងគួររកមើលគំរូជាតួយ៉ាង ដើម្បីយកមកធ្វើជាទិសដៅក្នុងការសរសេររបស់យើង ។ ប៉ុន្តែយើងមិនត្រូវចំលងតាមទេ គឺគ្រាន់តែអាចសុំខ្ចីវិធីតំណាលរឿងពីស្នាដៃនិពន្ធរបស់អ្នកនិពន្ធដែលយើងពេញចិត្ត ហើយយកមកសរសេរតាមទស្សនៈរបស់យើងផ្ទាល់បាន ។

ជួនកាលការរៀបគ្រោងរឿងអាចជួយយើងបានខ្លះៗដែរ ។ អ្នកនិពន្ធខ្លះក៏ប្រើការរៀបគ្រោងរឿងត្រួសៗ ដោយមានតួអង្គសំខាន់ៗបីបួននាក់ដើម្បីអាចកាត់បន្ថយក្តីកង្វល់បានខ្លះ រឺអាចធ្វើអោយអ្នកនិពន្ធមានជំនឿជាក់លើខ្លួនឯងកាន់តែច្រើនឡើង ព្រោះបានដឹងថាត្រូវធ្វើយ៉ាងណាខ្លះ ។ ម្យ៉ាងទៀតការរៀបគ្រោងរឿងអាចជួយអោយយើងសរសេរដំនើររឿងទៅតាមអ្វី ដែលយើងបានកំនត់ហេតុការណ៍រួចហើយ ។ ប៉ុន្តែយើងត្រូវតែដឹងថា យើងមិនអាចនឹងដាក់អ្វីៗគ្រប់បែបយ៉ាងទៅក្នុងគ្រោងរឿងបានទេ ដូចជា ចំនុចតូចៗរបស់តួអង្គ រឺហេតុការណ៍ដែលអាចនឹងកើតមានឡើង នៅពេលដែលយើងសរសេរជាបណ្តើរៗទៅនោះ ។ ដូចនេះ បើសិនយើងផ្តោតតែលើគ្រោងរឿងខ្លាំងហួសពេក នោះរឿងដែលយើងសរសេរក៏មិនបានល្អបំផុត ដូចដែលយើងចង់បានឡើយ ។ ផ្ទុយទៅវិញ បើសិនណាយើងមិនបានរៀប

www.elibraryofcambodia.org

គ្រោងរឿងជាមុនទេ តើយើងអាចនឹងសរសេររឿងបានដែរឬយ៉ាងណា? គឺវាអាស្រ័យលើការថ្នឹករបស់អ្នកនិពន្ធម្នាក់ៗ។

កាលបើយើងបានសរសេរល្បះដំបូង បានសរសេរកថាខណ្ឌដំបូងរួចហើយ ពេលដែលយើងសរសេរល្បះបន្តទៅទៀត សរសេរកថាខណ្ឌបន្តទៀត ស្រាប់តែយើងមានអារម្មណ៍ថាមិនពេញចិត្ត នោះយើងគួរតែសរសេរជាថ្មី ចាប់ផ្ដើមជាថ្មី...

បើគ្រាន់តែថា វាជាការងាយ តែបើយើងធ្វើ វាមិនងាយដូចថានោះទេ។ ពេលសរសេរហើយ យើងត្រូវតែអានហើយអានទៀត ហើយជួនកាលយើងមិនពេញចិត្ត តែក៏មិនដឹងថាមកពីហេតុអ្វី?... យើងចង់សរសេរអោយបានល្អជាងនេះ ពេលនោះយើងគួរតែសរសេរម្ដងទៀត។ ប៉ុន្តែបើយើងនៅតែមិនដឹងថាត្រូវសរសេរយ៉ាងដូចម្ដេច ដើម្បីអោយវាខុសពីសំនៅមុនសោះ... បើសិនសរសេរបែបផ្សេងប្រហែលជាល្អជាង... តែយើងគ្មានជំនឿជាក់ថាយើងមិនទាល់គំនិតទៀតទេ...

បើសិនជាយើងបានជួបបញ្ហាដូចរៀបរាប់ខាងលើនេះ មធ្យោបាយដែលល្អគឺយើងត្រូវតែផ្អាកសរសេរសិន។ ក្រោយមកយើងសរសេរខ្លីៗ សរសេរយ៉ាងលឿន សរសេរអោយបានច្រើនបែប ក្នុងមួយបែបៗសរសេរប្រមាណពី ៣-៤ កថាខណ្ឌ ដោយពុំចាំបាច់រិះគិតថា ល្អឬមិនល្អឡើយ។ ពេលយើងសាកល្បងធ្វើបែបនេះច្រើនលើកច្រើនសាទៅ យើងក៏ចាប់ផ្ដើមមានបទពិសោធ យើងក៏ថ្នឹកដៃក្នុងការសរសេរផ្ដើមរឿង ព្រោះយើងចាប់ផ្ដើមធ្លាប់បានរៀបពាក្យ ធ្លាប់បានរៀងលំដាប់ល្បះ និងបានយល់ដឹងពីវិធីផ្ដើមរឿងច្រើនបែប។ ជាពិសេសយើងអាចនឹងដឹងថាវិធីណាមួយដែលអាចទាក់ទាញចំនាប់អារម្មណ៍របស់យើងបានផងដែរ។

www.elibraryofcambodia.org

## ទំរង់នៃការតំណាលរឿងប្រលោមលោក

អ្នកនិពន្ធម្នាក់ៗអាចថ្មីកក្នុងការសរសេររឿងផ្សេងៗពីគ្នា ។ អ្នកខ្លះចូលចិត្តប្រើការសន្ទនាច្រើន ។ ឯអ្នកខ្លះចូលចិត្តប្រើការពណ៌នាពីបុគ្គលិកលក្ខណៈ ពណ៌នាពីការស្លៀកពាក់ ពណ៌នាពីការតុបតែងខ្លួន ពណ៌នាពីផ្ទះសំបែងរបស់តួអង្គ ។ ចំនែកអ្នកខ្លះទៀតចូលចិត្តផ្ដោតលើបរិយាកាសភូមិសាស្រ្តនិងធម្មជាតិ ។ រីឯអ្នកនិពន្ធខ្លះសរសេរចូលជ្រៅទៅក្នុងការនឹកគិតរបស់តួអង្គ ។

សំរាប់យើងដែលជាអ្នកនិពន្ធថ្មី ត្រូវតែអានប្រលោមលោករឿងដែលយើងពេញចិត្ត នោះយើងមុខជាអាចរកឃើញថាក្នុងប្រលោមលោករឿងនោះ អ្នកនិពន្ធបានប្រើវិធីតំណាលរឿងមួយណាច្រើនបំផុត ។ ទន្ទឹមនឹងនោះយើងត្រូវសង្កេតមើលតួយ៉ាងវិធីផ្ដើមរឿងរបស់អ្នកនិពន្ធជំនាន់មុន ហើយតាមរយៈការសង្កេតមើលនោះយើងមុខជាអាចនឹងយល់ដឹងបានខ្លះៗថា វិធីតំណាលរឿងនីមួយៗមានសារៈសំខាន់ក្នុងការសរសេររឿងដូចគ្នា ។

www.elibraryofcambodia.org

## តួអង្គ

តួអង្គក្នុងរឿងប្រលោមលោក ជាមនុស្សដែលមិនមានរូបពិត ជាមនុស្សដែលកើតពីតួអក្សរសុទ្ធសាធ ។ តួអង្គដែលយើងនឹងតែងឡើងតួរមានអ្វីៗដូចមនុស្សទូទៅដែរ តែវាអាចទៅរួចរឺមិនរួចអាស្រ័យលើអ្នកនិពន្ធឬវិចិត្រករអក្សរជាអ្នកគួររឺបង្កើតតួអង្គឡើងមកដោយខ្លួនឯងផ្ទាល់ ។

តួអង្គជាអ្នកបង្កើតគ្រោងរឿង ហើយតួអង្គដែលល្អអាចធ្វើអោយអ្នកអានយល់ពីគោលបំនងរបស់រឿងប្រលោមលោកបានល្អ ។ ដូចនេះបើសិនណាយើងអាចយល់ពីតួអង្គរបស់យើងបានស៊ីជំរៅ និងអាចធ្វើអោយអ្នកអានបានស្គាល់តួអង្គដូចដែលយើងបានស្គាល់ដែរ នោះយើងអាចនឹងទទួលបានជោគជ័យក្នុងការសរសេររឿង ។ ម្យ៉ាងទៀតយើងត្រូវធ្វើយ៉ាងណាអោយអារម្មណ៍អ្នកអានជិតជាប់ជាមួយតួអង្គជានិច្ច ។

ប្រលោមលោកដែលល្អអាចធ្វើអោយអ្នកអាចបានជួបនឹងនរណាម្នាក់ដែលអ្នកអានធ្លាប់បានស្គាល់និងយល់បានស៊ីជំរៅ រឺអាចបានជួបខ្លួនឯង តាមរយៈតួអង្គក្នុងរឿងដែលមានអ្វីៗ ដូចអ្នកអានដែរ ។ បើតួអង្គមានភាពសំខាន់សំរាប់អ្នកអាន នោះភាពសំខាន់នេះ ក៏កាន់តែទ្វេឡើងទៀតសំរាប់អ្នកនិពន្ធ ។ ដូចនេះបើសិនយើងបង្កើតតួអង្គបានសមល្អហើយ នោះអ្វីៗផ្សេងៗទៀតក៏ងាយដែរ ។

អ្នកនិពន្ធខ្លះយល់ថា"**តួអង្គ គឺគ្រោងរឿង និងគ្រោងរឿង គឺតួអង្គ**" តែអ្នកនិពន្ធខ្លះទៀតយល់ថា"យើងអាចបង្កើតគ្រោងរឿងពីតួអង្គបាន តែបើមិនមាន

www.elibraryofcambodia.org

គ្រោងរឿងទេ យើងក៏មិនអាចបង្កើតតួអង្គបានដែរ ។ ទោះជាយ៉ាងណាក្ដីយើងជាអ្នកនិពន្ធ គឺជាអ្នកជ្រើសរើសដោយខ្លួនឯង ថាតើគួរធ្វើអ្វីមុនក្នុងរឿងដែលយើងចង់សរសេរនោះ ។

ចំពោះការយល់ឃើញផ្សេងពីគ្នាខាងលើនេះ វាមុខជា[illegible]ហួតទៅ... ចុះតើនរណាហ៊ានប្រកែកថាអ្នកអានមិនចាំតួអង្គ និងមិនផ្ដោតអារម្មណ៍លើតួអង្គច្រើនជាងគ្រោងរឿង? យើងសាងល្បងនឹកគិតដល់រឿងដែលយើងបានចាំ ហើយឆ្លើយដោយខ្លួនឯងថា រវាងតួអង្គនិងគ្រោងរឿង មួយណាដែលសំខាន់ជាង ។

តាមការសង្កេតជាទូទៅឃើញថា តួអង្គដែលអ្នកអានមិនអាចបំភ្លេចបានគឺជាអ្វីដែលសំខាន់ អាចធ្វើអោយអ្នកអានចងចាំរឿងនោះបានយូរ ។ ផ្ទុយទៅវិញបើអ្នកអានចងចាំឈ្មោះតួអង្គមិនបានទេ រឿងនោះក៏មិនអាចល្បីបានយូរដែរ ។

**មធ្យោបាយក្នុងការបង្កើតតួអង្គ**

ពេលយើងបង្កើតតួអង្គអោយសមតាមការពិត យើងត្រូវបញ្ចូលព័ត៌មានសំអិតម្ដងបន្តិចៗអោយតួអង្គ ។ មានន័យថា យើងបានស្គាល់តួអង្គរបស់យើងយ៉ាងច្បាស់ មុននឹងយើងណែនាំអោយអ្នកអានស្គាល់ ។

ឧបមាថា យើងសរសេររឿងរបស់គូស្នេហ៍មួយ ដែលទើបនឹងលែងលះគ្នា ហើយដើម្បីអាចនឹងសរសេររឿងនោះបាន យើងត្រូវដឹងប្រវត្តិរបស់គូស្វាមីភរិយានោះជាមុនសិន ។ យើងសាកល្បងលើកជាឧទាហរណ៍ ចោទជាសំនួរសួរខ្លួនឯងរួចឆ្លើយដោយខ្លួនឯង ព្រោះកាលបើយើងដឹងពីប្រវត្តិជីវិតរបស់គូស្វាមីភរិយានោះច្រើនប៉ុនណា នោះយើងក៏ងាយស្រួលក្នុងការសរសេរប៉ុននោះដែរ ។

www.elibraryofcambodia.org

ឧទាហរណ៍ :

-យើងចោទសួរថាតើភរិយាឈ្មោះអ្វី? នាងអាយុប៉ុន្មាន? នាងស្អាតរឺទេ? ស្ថានភាពគ្រួសារដើមរបស់នាងបែបណា? ឪពុកម្តាយរបស់នាងធ្លាប់ឈ្លោះគ្នាដែររឺទេ? គ្រួសារដើមរបស់នាងមានអាចិកំបាំងអ្វី ហើយនាងដឹងអាចិកំបាំងនោះដែររឺទេ? នាងមានទំលាប់មិនល្អអ្វីខ្លះ? គេមានអ្នកបំរើរឺទេ? ជាពិសេស តើហេតុអ្វីបានជានាងរៀបការជាមួយស្វាមីនោះ?...

-យើងចោទសួរថា តើស្វាមីឈ្មោះអ្វី? គេអាយុប៉ុន្មាន? គេស្អាតរឺទេ? ស្ថានភាពគ្រួសារដើមរបស់គេបែបណា? គេមានទំលាប់មិនល្អអ្វីខ្លះ? គេមានកូនរឺនៅ បើមានតើគេស្រលាញ់កូនរឺទេ? ស្ថានភាពសេដ្ឋកិច្ចគ្រួសារយ៉ាងណា? គេមានទាក់ទងនឹងស្រីថ្មីទៀតរឺទេ? ហេតុអ្វីបានជាគេរៀបការជាមួយភរិយានោះ?...

កាលបើយើងបានធ្វើការចោទសួរ បានឆ្លើយនឹងសំនួរដោយខ្លួនឯងផ្ទាល់ជំនួសអោយតួអង្គទាំងនោះ ចៃដន្យតួអង្គអាចឆ្លើយថា គេលែងលះគ្នាព្រោះមានបញ្ហាជាច្រើន ដូចជា :

បើយើងសរសេររឿងដោយយកទស្សនៈរបស់ស្វាមីជាគោល នោះយើងអាចនឹងស្រាវជ្រាវរកឃើញអ្វីៗផ្សេងទៀត ដែលខុសប្លែកពីទស្សនៈរបស់ភរិយា ដូចជា គេអាចនិយាយថា អ្វីដែលធ្វើអោយគេទ្រាំមិនបាន គឺរឿងផ្ទាល់ខ្លួនរបស់ភរិយា ដែលស្វាមីនោះអាចនឹងលើកយកមកធ្វើជាលេស...

បើយើងសរសេររឿងដោយយកទស្សនៈរបស់ភរិយាជាគោល នោះយើង

www.elibraryofcambodia.org

អាចនឹងស្រាវជ្រាវរកឃើញរឿងក្តីផ្សេងទៀត ដែលខុសប្លែកពីទស្សនៈរបស់ស្វាមី ដូចជា នាងអាចនិយាយថា បុរសនេះមិនសមនឹងធ្វើជាស្វាមីរបស់នាងទេ... ហើយ កូននេះក៏មិនមែនជាកូនរបស់អតីតស្វាមីនាងដែរ ។

ការលើកជាឧទាហរណ៍ខាងលើនេះ អ[illegible]ជាការពិតហួសពេកសំរាប់រឿង [illegible]ោមលោករបស់យើង [illegible]យើង[illegible]តែបង្កើតតួអង្គដែលមានកំហុសឆ្គងពិតមែន ។ ប៉ុន្តែការពិតដែលមានក្នុងមនោវិញ្ញាណ មានក្នុងរូបារម្មណ៍ ជាអ្វីដែលយើងត្រូវស្រាវជ្រាវរកឱ្យឃើញ ដើម្បីយកមកសរសេររឿង ។

យើងជាអ្នកនិពន្ធ ជាអ្នករៀងលំដាប់ពាក្យពេចន៍ ជាអ្នកគូររូបដោយប្រើតួ[illegible]ជាអ្នកកំនត់របៀបអោយតួអង្គ ជាអ្នកផ្តល់រង្វាន់ដល់តួអង្គ និងក៏ជាអ្នកផ្តន្ទាទោសដល់តួអង្គ ។ ល ។ និង ។ ល ។ ដូចនេះយើង[illegible]និងជាអ្នកសំរេចដោយខ្លួនឯងថា គួរដាក់ទោសដល់តួអង្គណា? [illegible]បានទទួលផលល្អរឺទេ? គួរទទួលនៅពេលណា? ចំនែកមនុស្សចិ[illegible]បាបកម្មដែលគេបានសាងប៉ុនណា?...

សំនួរខាងលើនេះ មានតែយើងដែលជាអ្នកសរសេរតែម្នាក់ប៉ុណ្ណោះ ដែលអាចនឹងឆ្លើយបាន ។ យើងអាចនឹងរិះគិតរកចំលើយឃើញ លុះណាតែខ្លួនយើងបានស្គាល់តួអ[illegible]មរយៈការចោទជាសំនួរ សួរខ្លួនឯងច្រើនបែបច្រើនយ៉ាង និងច្រើនលើកច្រើនសាផង ។ ថ្វីបើយើងអាចនឹងមិនបានប្រើគ្រប់ចំលើយទាំងនោះ ក្នុងរឿងរបស់យើងក្តី តែយើងក៏ត្រូវតែដឹងដដែល ដើម្បីធ្វើអោយយើងអាចនឹងដឹងបានថា តួអង្គត្រូវធ្វើអ្វី? ត្រូវធ្វើយ៉ាងដូចម្តេច? ត្រូវសំរេចចិត្តយ៉ាងណា? នៅពេលដែល

www.elibraryofcambodia.org

កើតមានប្រការល្អេវប្រការអាក្រក់ក្នុងគ្រោងរឿង។

តួអង្គត្រូវតែជាទីចាប់អារម្មណ៍របស់អ្នកអាន តួអង្គត្រូវតែមានថាមពលអាចទាក់ទាញអោយអ្នកអានចង់តាមដានរឿង។ ប៉ុន្តែអ្វីទាំងនេះ វាមិនមែនមានន័យថា តួអង្គត្រូវតែស្រស់ស្អាត សង្ហា មាំមួន ជាមនុស្សល្អ រឺឈ្លាសវៃនោះទេ។ ផ្ទុយទៅវិញ បើសិនយើងបង្កើតតួអង្គដែលអាក្រក់ ហើយអាចធ្វើអោយភាពអាក្រក់របស់គេនោះ មើលទៅគួរអោយចាប់អារម្មណ៍វិញ ដូចជា បើកាចក៏អោយកាចប្រភេទដែលអ្នកអានបះសក់ រឺព្រឺរោមខ្នាក១... តែអ្វីដែលយើងគួរចងចាំ គឺការពិតលើលោកនេះមិនមាននរណាល្អទាំងអស់ រឺអាក្រក់ទាំងអស់នោះទេ។ ដូចនេះយើងត្រូវតែប្រុងប្រយ័ត្នក្នុងការបង្កើតតួអង្គដែលគួរអោយជឿ ដូចជាតួអាក្រក់ក៏អោយមានចំនុចល្អខ្លះផង តួឯកក៏មានចំនុចមិនល្អខ្លះដែរ ទោះជាមានតិចតួចក្តី។

**មធ្យោបាយធ្វើអោយអ្នកអានអាណិតយល់ដល់ចិត្តតួអង្គ**

យើងគួរអោយតួអង្គត្រូវរងនូវការគំរាមកំហែង ឈ្លានីស ពីសំនាក់គូគ្រង ពីឪពុកម្តាយក្មេករឺសាច់ថ្លៃ ពីឪពុករឺម្តាយចុង... យើងត្រូវធ្វើអោយតួអង្គនោះប៉ងប្រាថ្នាចង់បានក្តីសុខ ពេលនោះអ្នកអានអាចនឹងអាណិតយល់ដល់ចិត្តតួអង្គ ហើយចង់ជួយតួអង្គ ព្រោះអ្នកអានទទួលអារម្មណ៍ថាខ្លួនគេក៏ត្រូវរងនូវការគំរាមកំហែងរឺមានកាឈ្លានីសដូចតួអង្គដែរ។

យើងធ្វើយ៉ាងណាអោយតួអង្គមានការតាំងចិត្ត ព្យាយាម មានបំនងល្អតែមានអ្នកមករារាំង មានអ្នកមើលងាយមើលថោក មានអ្នកមួលបង្កាច់ជាដើម។

www.elibraryofcambodia.org

បើសិនតួអង្គមានការតស៊ូពុះពារ អង់អាចក្លាហាន អ្នកអានក៏ចង់អោយតួអង្គនោះទទួលបានជោគជ័យ ។ ពេលតួអង្គនោះប្រឈមមុខនឹងគ្រោះថ្នាក់ អ្នកអានក៏កាន់ជើងភ្លាម ។ ដូចគ្នានេះដែរពេលតួអង្គត្រូវគេបោក ត្រូវគេធ្វើបាប រឺក៏ត្រូវអ្នកនិពន្ធធ្វើអោយមើលទៅហាក់ដូចជាអោតរឹលូវង់ហួសពេក ជាដើម អ្នកអានក៏មានចិត្តនឹកអាណិតតួអង្គ ។ ផ្ទុយទៅវិញបើយើងសរសេររឿងដែលតួឯកមានក្ដីសុខនោះ ពិតជាធ្វើអោយអ្នកអានគ្មានការចាប់អារម្មណ៍ ហើយមានការធុញទ្រាន់ ។

ប៉ុន្តែយើងជាអ្នកនិពន្ធត្រូវតែប្រុងប្រយ័ត្នជានិច្ច គឺយើងសរសេរយ៉ាងណាកុំអោយតួអង្គនោះតបតវិញ ដោយអំពើហឹង្សាខ្លាំងហួសពេក **ឧទាហរណ៍** ដូចជាបើយើងអោយតួអង្គសំលាប់អ្នកដែលធ្វើបាបខ្លួនវិញ នោះការអាណិតយល់ដល់ចិត្តរបស់តួអង្គពីសំនាក់អ្នកអានក៏នឹងថយចុះ រឺអាចក្លាយជាការមិនពេញចិត្តទៅវិញ ។

ការស្វែងយល់អំពីវិធីបង្កើតតួអង្គ វាអាចជាអ្វីដែលសំខាន់បំផុតក្នុងការស្វែងយល់អំពីវិធីសរសេរប្រលោមលោក ព្រោះសូម្បីតែគ្រោងរឿងក៏ជាអ្វីដែលតួអង្គជាអ្នកធ្វើអោយកើតឡើងដែរ ។ ពោលគឺបើគ្មានតួអង្គទេ យើងក៏មិនអាចនឹងរៀបគ្រោងរឿងបានដែរ ។ ដូចនេះពេលមានបញ្ហាក្នុងការសរសេររឿង យើងអាចនឹងដោះស្រាយបញ្ហាបាន ដោយងាកត្រលប់មករិះគិតកែលំអតួអង្គតាមរយៈទង្វើរបស់តួអង្គជាថ្មីម្ដងទៀត ។

www.elibraryofcambodia.org

បើសិនតួអង្គមានការតស៊ូពុះពារ អុងអាចក្លាហាន អ្នកអានក៏ចង់អោយតួអង្គនោះទទួលបានជោគជ័យ ។ ពេលតួអង្គនោះប្រឈមមុខនឹងគ្រោះថ្នាក់ អ្នកអានក៏កាន់ជើងភ្លាម ។ ដូចគ្នានេះដែរពេលតួអង្គត្រូវគេបោក ត្រូវគេធ្វើបាប រឺក៏ត្រូវអ្នកនិពន្ធធ្វើអោយមើលទៅហាក់ដូចជាឆោតរីល្ងង់ហួសពេក ជាដើម អ្នកអានក៏មានចិត្តនឹកអាណិតតួអង្គ ។ ផ្ទុយទៅវិញបើយើងសរសេររឿងដែលតួឯកមានក្តីសុខនោះ ពិតជាធ្វើអោយអ្នកអានគ្មានការចាប់អារម្មណ៍ ហើយមានការធុញទ្រាន់ ។

ប៉ុន្តែយើងជាអ្នកនិពន្ធត្រូវតែប្រុងប្រយ័ត្នជានិច្ច គឺយើងសរសេរយ៉ាងណាកុំអោយតួអង្គនោះតបតវិញ ដោយអំពើហឹង្សាខ្លាំងហួសពេក **ឧទាហរណ៍** ដូចជាបើយើងអោយតួអង្គសំលាប់អ្នកដែលធ្វើបាបខ្លួនវិញ នោះការអាណិតយល់ដល់ចិត្តរបស់តួអង្គពីសំនាក់អ្នកអានក៏នឹងថយចុះ រឺអាចក្លាយជាការមិនពេញចិត្តទៅវិញ ។

ការស្វែងយល់អំពីវិធីបង្កើតតួអង្គ វាអាចជាអ្វីដែលសំខាន់បំផុតក្នុងការស្វែងយល់អំពីវិធីសរសេរប្រលោមលោក ព្រោះសូម្បីតែគ្រោងរឿងក៏ជាអ្វីដែលតួអង្គជាអ្នកធ្វើអោយកើតឡើងដែរ ។ ពោលគឺបើគ្មានតួអង្គទេ យើងក៏មិនអាចនឹងរៀបគ្រោងរឿងបានដែរ ។ ដូចនេះពេលមានបញ្ហាក្នុងការសរសេររឿង យើងអាចនឹងដោះស្រាយបញ្ហាបាន ដោយងាកត្រលប់មករិះគិតកែលំអតួអង្គតាមរយៈទង្វើរបស់តួអង្គជាថ្មីម្តងទៀត ។

www.elibraryofcambodia.org

# ការបង្កើតតួអង្គ

យើងក្នុងនាមជាអ្នកនិពន្ធត្រូវបំពេញតួនាទី ជាអ្នកផ្តល់កំនើត ជាគ្រូពេទ្យផ្នែកចិត្តសាស្ត្រ ជាអ្នកនាំតួអង្គចូលសង្គមក្នុងរឿង និងជាមិត្តរបស់តួអង្គផង ទើបយើងអាចយកទឹកខ្មៅសូន្យធ្វើជាតួអង្គ អោយដូចជាមនុស្សមានជីវិតពិតបាន ។

ថ្វីបើគ្រោងរឿងជាអ្វីដែលសំខាន់ក្នុងការសរសេររឿង ប៉ុន្តែហេតុការណ៍ដែលអាចបង្កើតបានជាគ្រោងរឿងត្រូវកើតមកពីសកម្មភាពរបស់តួអង្គ ។ ដូចនេះយើងជាអ្នកនិពន្ធចាំបាច់ត្រូវតែស្គាល់តួអង្គអោយបានច្រើនបំផុត ។

**យើងគួរ "បង្ហាញ" ប្រសើរជាង "ប្រាប់"**

**"សំដីសជាតិ មារយាទសត្រកូល"** សុភាសិតនេះជាគំរូមួយដ៏ល្អអាចយកមកប្រើជាមួយនឹងការធ្វើអោយអ្នកអានឃើញរូបភាពរបស់តួអង្គក្នុងរឿង ដែលយើងចង់អោយអ្នកអានបានស្គាល់ ។

ប៉ុន្តែវាជាការលំបាកដែរ ក្នុងការសរសេររឿងមួយដោយពុំមានការប្រាប់អ្នកអាននោះ ។ ដូចនេះ ជួនកាលយើងអាចអោយតួអង្គជាអ្នកប្រាប់ជំនួសអ្នកនិពន្ធ **ដោយប្រើការសន្ទនា។ ឧទាហរណ៍** ដូចជា "ខ្ញុំគិតថាគេជាមនុស្សអាត្មានិយមមែន" រឺអ្នកនិពន្ធជាអ្នកប្រាប់ ដោយប្រើកថាខណ្ឌដែលមិនវែងហួសពេក ក្នុងករណីដែលអ្នកនិពន្ធមិនមានពេលសំរាប់សរសេរបង្ហាញដល់អ្នកអាន ។

ទោះជាយ៉ាងណាយើងក៏គួរតែប្រើវិធីបង្ហាញអោយច្រើនបំផុត ព្រោះវិធី

www.elibraryofcambodia.org

បង្ហាញនោះ អាចជួយអោយអ្នកអានស្គាល់និងយល់ដឹងពីតួអង្គ ល្អជាងការប្រាប់ ។

**"បើត្រូវបានអ្នកនិពន្ធប្រាប់ អ្នកអានហាក់ដូចជាបានស្តាប់គេមកតំណាលបន្ត"**

**"បើត្រូវបានអ្នកនិពន្ធបង្ហាញ អ្នកអានហាក់ដូចជាបានឃើញផ្ទាល់"**

ពេលយើងបង្ហាញ (Show) អ្នកអានអាចនឹងដឹងពីអ្វីដែលអ្នកនិពន្ធដឹងដែរ តែអ្នកអានមានសិទ្ធិនិងមានសេរីភាពក្នុងការកាត់សេចក្តីដោយខ្លួនឯងផ្ទាល់ ចំពោះសកម្មភាពរបស់តួអង្គនោះ ។ ឧទាហរណ៍ ជួនកាលអ្នកអានខ្លះអាចស្អប់ប្រពន្ធរបស់ខ្លួន ហើយគេមានអារម្មណ៍ថា គ្មានអ្វីប្លែកសោះ ពេលឃើញបុរសណាម្នាក់វាយដំប្រើអំពើហិង្សាលើភរិយា ។ អ្នកអានរូបនោះគេមានសិទ្ធិកាន់ជើងបុរសដែលធ្វើបាបប្រពន្ធ ដោយអ្នកនិពន្ធមិនអាចធ្វើអ្វីបានក៏មាន ។

ជំនួសអោយការប្រាប់រឺកាត់សេចក្តីតួអង្គរបស់យើងដោយខ្លួនយើងដែលជាអ្នកនិពន្ធតែម្នាក់ឯង យើងត្រូវតែពិនិត្យរកចន្លោះអោយតួអង្គបានបញ្ចេញសកម្មភាពជានិច្ច ក្នុងខណៈពេលដែលយើងកំពុងសរសេររឿងប្រលោមលោក ដើម្បីអោយអ្នកអានអាចមើលឃើញថា តួអង្គនោះជាមនុស្សបែបណា ។ ការបង្ហាញ ជាការបង្កើតនូវភាពច្បាស់ កាន់តែស៊ីជំរៅ ធ្វើអោយតួអង្គមានជីវិតរស់រវើកនៅលើទំព័រក្រដាស ដោយយើងក្នុងនាមជាអ្នកនិពន្ធបានជួយអោយតួអង្គអាចធ្វើអ្វីៗបានដូចជាមនុស្ស ដែលមានជីវិតពិតដែរ ។

សកម្មភាព (Action) របស់តួអង្គ ក្រៅពីធ្វើអោយអ្នកអានដឹងថា តួអង្គនោះជាមនុស្សបែបណា វាថែមទាំងមានភាពសំខាន់ក្នុងការដំនើររឿងទៀតផង ។ តួអង្គទាំងអស់ដែលយើងបានបង្កើតឡើងក្នុងរឿងរបស់យើង ទាំងតួឯកនិងតួរង

www.elibraryofcambodia.org

ទោះជាតួនោះមិនសូវជាចេញមុខឬចេញមុខតែម្តងពីរក្តី យើងសុទ្ធតែអាចសរសេរ បង្ហាញពីសកម្មភាពរបស់គេបានទាំងអស់ ។

**មធ្យោបាយក្នុងការសំលឹងរកតួអង្គ នឹងសន្សំរូបភាពតួអង្គ**

យើងគួរស្វែងរកទស្សនាវដ្តី ឬសារព័ត៌មាន ហើយយកមកបើករកមើល រូបភាពមនុស្សល្បីៗ មនុស្សជិតនឹងល្បី ឬមនុស្សដែលអ្នកផងទាំងឡាយមិនសូវជាស្គាល់ប៉ុន្មានទេ ។ បន្ទាប់មកយើងសំលឹងរករូបភាពណាដែលយើងគិតថា អាចយកមកធ្វើជាតួអង្គក្នុងរឿងរបស់យើងបាន ។ បើសិនបានរូបភាពតាំងពីសក់ដល់ចុងជើងកាន់តែប្រសើរ ហើយយកកន្ត្រៃកាត់រូបភាពនោះ រួចដាក់ទុកក្នុងសៀវភៅ ឬក្នុងប្រអប់សន្សំរូបភាពរបស់យើង ។

ម្យ៉ាងទៀតយើងក៏អាចនឹងស្វែងរករូបភាពតួអង្គ ពីសៀវភៅដាក់រូបថតក្នុងផ្ទះរបស់យើង សៀវភៅរូបថតរបស់មិត្ត ឬសាច់ញាតិ ។ យើងបើកមើល ហើយជ្រើសរើសរករូបថតមនុស្សណាដែលមានមុខមាត់ដូច ឬក៏ស្រដៀងគ្នានឹងតួអង្គរបស់យើង ហើយយកមកសន្សំទុកក្នុងប្រអប់សន្សំរូបភាពរបស់យើងដែរ ។

ទង្វើដូចខាងលើនេះអាចជួយអោយយើងបំបាត់កង្វល់ក្នុងពេលដែលយើងត្រូវសរសេរពណ៌នាពីតួអង្គ ។ ជាពិសេសតួអង្គសំខាន់ ដូចជា តួឯកប្រុស តួឯកស្រីក្នុងរឿងរបស់យើង ។ ពេលនោះយើងអាចទាញយករូបភាពឬរូបថតនោះចេញមក ហើយសរសេរឈ្មោះតួអង្គដាក់ពីក្រោម ។ ពេលយើងត្រូវពណ៌នារៀបរាប់ពីមុខមាត់ រូបសណ្ឋានរបស់តួអង្គ យើងក៏អាចយកលំនាំតាមរូបនោះបានខ្លះដែរ ។

មួយវិញទៀតយើងក៏អាចប្រើវិធីដូចខាងលើនេះ ដើម្បីនឹងសន្សំរូបភាព

www.elibraryofcambodia.org

ទេសភាពនានា ពីសៀវភៅរូបភាពសំរាប់ទេសចរណ៍បានដែរ ។

**ចំនុចគួរប្រុងប្រយ័ត្នក្នុងការស្វែងរករូបភាពតួអង្គ**

យើងមិនគួរជ្រើសរើសយកតែមនុស្សស្អាត មនុស្សសង្ហានោះទេ ។ យើងគួរសំលឹងរកមនុស្សពាក់វ៉ែនតា រឺមនុស្សក្បាលទំពែក គួរសំលឹងរករូបភាពមនុស្សទាំងធាត់ទាំងស្គម ទាំងល្អមសម ទាំងសទាំងខ្មៅ រួមទាំងមនុស្សមានស្នាកស្នាមដំបៅរឺពិការផងដែរ ។ ពេលគឺយើងគួរបង្កើតតួអង្គដែលមានលក្ខណៈរូបរាងផ្សេងៗតាមការស្រមើស្រម៉ៃរបស់យើង ។ ប៉ុន្តែយើងមិនគួរជ្រើសរើសបង្កើតតួអង្គដែលជាមនុស្សស្អាត រឺសង្ហាហួសពីការពិតពេកនោះទេ ។

មួយវិញទៀត យើងមិនគួរប្រើរូបភាពរបស់មនុស្សល្បីដែលនរណាក៏ស្គាល់យកមកធ្វើការពណ៌នាតាមរូបរាងទាំងអស់ទេ ។ ពោលគឺ យើងបង្កើតអោយតួអង្គមានទ្រង់ទ្រាយជាលក្ខណៈពិសេសដោយឡែករបស់គេផ្ទាល់ ទើបល្អជាង ។ ទោះជាយ៉ាងណាក្តី យើងមិនត្រូវផ្តោតអារម្មណ៍លើការសន្សំរូបភាពតួអង្គច្រើនហួសពេកទេ ព្រោះវាអាចធ្វើអោយយើងសរសេររឿងមិនងាយនឹងចប់ ។

**គួររៀបចំធ្វើបញ្ជីរាយនាមតួអង្គមុនចាប់ផ្តើមសរសេររឿង**

ការដាក់ឈ្មោះតួអង្គមុនពេលចាប់ផ្តើមសរសេររឿងអាចជួយអោយយើងមានភាពងាយស្រួលជាងការសរសេរបណ្តើរ គិតរកឈ្មោះដាក់បណ្តើរ ។ ហេតុនេះយើងគួរតែធ្វើបញ្ជីរាយនាមតួអង្គត្រៀមទុកជាមុន ។ ប៉ុន្តែយើងត្រូវជ្រើសរើសដាក់ឈ្មោះយ៉ាងណាអោយសមទៅនឹងសកម្មភាព កន្លែងរស់នៅ និងស្ថានភាពគ្រួសាររបស់តួអង្គនោះផង ។

www.elibraryofcambodia.org

**បញ្ជីរាយឈ្មោះតួអង្គ**

| ឈ្មោះតួអង្គប្រុស | ឈ្មោះតួអង្គស្រី |
|---|---|
| .................... | .................... |
| .................... | .................... |

ពេលយើងដាក់ឈ្មោះអោយតួអង្គហើយ ភ្លាមនោះយើងមានអារម្មណ៍ល្អឬមិនស្រួល យើងគួរសួរខ្លួនឯងថាមកពីឈ្មោះនោះដូចឈ្មោះមនុស្សដែលយើងធ្លាប់ស្គាល់ដែររឺទេ? តើយើងដាក់ឈ្មោះតួចិត្តអាក្រក់ថា "ក" ព្រោះតែយើងស្អប់មនុស្សឈ្មោះ "ក" ដែររឺទេ? តើយើងដាក់ឈ្មោះតួឯកស្រីថា "ខ" ព្រោះមនុស្សដែលយើងស្រលាញ់ឈ្មោះ "ខ" ដែររឺទេ? បើសិនដូចរៀបរាប់មកនេះ យើងត្រូវរិះគិតប្តូរឈ្មោះតួអង្គជាថ្មីម្តងទៀត ។

**មុននឹងសំរេចចិត្តដាក់ឈ្មោះអោយតួអង្គយើងគួរគិតដល់ប្រការទាំងនេះ**

ទោះបីជាបំនងល្អក្តី យើងក៏មិនត្រូវប្រើឈ្មោះមនុស្សដែលយើងស្គាល់ទេ ព្រោះអាចធ្វើអោយមិត្តដែលយើងយកឈ្មោះមកប្រើយល់ច្រលំ ។ ម្យ៉ាងវិញទៀតមនុស្សខ្លះ គេមិនចូលចិត្តអានរឿងរបស់ខ្លួនឯងទេ ទោះជារឿងនោះជារឿងពិត រឺជារឿងល្អក៏ដោយ ។

យើងមិនត្រូវដាក់ឈ្មោះតួអង្គក្នុងរឿងរបស់យើង ដូចឈ្មោះតួអង្គក្នុងរឿងចាស់ៗ ដែលល្បីៗនោះទេ ព្រោះអាចនឹងត្រូវអ្នកអានវាយតំលៃថាយើងមិន

www.elibraryofcambodia.org

មានសមត្ថភាពរកឈ្មោះដាក់អោយតួអង្គ ។

យើងមិនគួរដាក់ឈ្មោះអោយតួអង្គវែងពេកទេ ព្រោះគ្រាន់តែសរសេរ រឺអានឈ្មោះនោះក៏ធុញទៅហើយ ។ ប៉ុន្តែវាមិនមែនមានន័យថា យើងមិនអាចប្រើឈ្មោះតួអង្គវែងៗបាននោះទេ ។

**ការគូររូបតួអង្គដោយប្រើតួអក្សរ**

អ្នកនិពន្ធ ជាវិចិត្រករដែលប្រើតួអក្សរគូររូបភាព តាមរយៈការតំណាលរឿងអោយដល់អ្នកអាន ។ វិធីតំណាលរឿងប្រលោមលោកអាចចែកបាន ៥ វិធី :

១-ការលាតត្រដាងប្រាប់ (Exposition)

២-ការពណ៌នាពីរូបខាងក្រៅ (Appearance-looks)

៣-សកម្មភាព (Action)

៤-ការគិត (Thought)

៥-ការសន្ទនា (Dialogue)

**១-ការលាតត្រដាងប្រាប់** (Exposition)

(Narrator Direct Informotion)

វិធីតំណាលរឿងបែបនេះ អ្នកនិពន្ធសរសេរប្រាប់ត្រង់ៗតែម្តង ។ វិធីនេះគឺជាទំរង់ដែលធ្វើអោយអ្នកអានមើលឃើញព័ត៌មានលំអិតរបស់តួអង្គ បានតិចជាងវិធីដទៃទៀត រឺអាចនិយាយបានថា អ្នកអានឃើញរូបភាពតួអង្គមិនសូវច្បាស់ ។

**២-ការពណ៌នាពីរូបរាងខាងក្រៅ** (Apearance-looks)

ការពណ៌នា ជាវិធីតំណាលរឿងមួយដែលអាចនឹងធ្វើអោយអ្នកអាចមើលេ

www.elibraryofcambodia.org

ឃើញរូបភាពតួអង្គបានច្បាស់ជាងវិធីលាតត្រដាងប្រាប់មួយក៏រិតទៀត ព្រោះវាជាការបង្កើតរូបភាពដែលហាក់ដូចជាលំអិត ។

ក្នុងការសរសេររឿងប្រលោមលោក កាលពីសម័យមុនអ្នកនិពន្ធចូលចិត្តប្រើការពណ៌នាច្រើន ព្រោះកាលពីយុគសម័យមុនមិនទាន់មានបច្ចេកវិជ្ជាទំនើបដូចសព្វថ្ងៃនេះទេ។ ក្នុងយុគសម័យបច្ចុប្បន្ននេះប្រសិនបើយើងសរសេរដូចសម័យមុននោះ ប្រហែលជាមិនសូវមានអ្នកអានគាំទ្រច្រើនប៉ុន្មានទេ ។ ប៉ុន្តែទោះជាយ៉ាងណាយើងមិនត្រូវភ្លេចថា ការតំណាលរឿងបែបពណ៌នាមានភាពសំខាន់ ក្នុងការធ្វើអោយអ្នកអានឃើញរូបភាពនឹងស្គាល់តួអង្គរបស់យើងបាន ។ ដូចនេះយើងគួរសរសេរពណ៌នាយ៉ាងណាកុំអោយវែងពេក រឺខ្លីពេក ។ ពិសេសយើងត្រូវសិក្សាពីស្នាដៃរបស់អ្នកនិពន្ធដែលយើងពេញចិត្ត ដោយធ្វើការសង្កេតវិធីពណ៌នារបស់អ្នកនិពន្ធនោះៗ ហើយសំរេចចិត្តខ្លួនឯងថា ស្នាដៃរបស់អ្នកនិពន្ធណា ត្រូវបាន ធ្វើអោយឃើញរូបភាពតួអង្គតាមរយៈការពណ៌នារបស់អ្នកនិពន្ធបានច្បាស់ជាង ។

**៣-សកម្មភាព** (Action)

វិធីតំណាលរឿងតាមរយៈសកម្មភាព( ការបង្ហាញ) ជាវិធីដែលផ្តល់ផលច្រើនបំផុត ក្នុងការធ្វើអោយអ្នកអានស្គាល់តួអង្គក្នុងរឿងប្រលោមលោក ។ ថ្វីបើវិធីនេះត្រូវប្រើការរិះគិតបន្តិចក៏ពិតមែន តែសកម្មភាពអាចធ្វើអោយអ្នកអានដឹងពីជីវិត ឧបនិស្ស័យរបស់តួអង្គនោះៗ ។ ម្យ៉ាងទៀតសកម្មភាពរបស់តួអង្គអាចនឹងទាក់ទាញចំនាប់អារម្មណ៍របស់អ្នកអានបានល្អទៀតផង ។ ដូចនេះការតំណាលរឿងតាមរយៈសកម្មភាពរបស់តួអង្គអាចបង្កើតបានជារូបភាពស្ថិតនៅក្នុងខ្សែភ្នែក ស្ថិត

www.elibraryofcambodia.org

នៅក្នុងគំនិតរបស់អ្នកអានបានល្អជាងការតំណាលរឿងបែបលាតត្រដាងប្រាប់និងការពណ៌នាផងដែរ ។

**៤-ការគិត** (Thought)

បើយើងប្រើការតំណាលរឿងតាមរយៈការគិតរបស់តួអង្គ អ្នកអានអាចនឹងស្គាល់តួអង្គរបស់យើងបាន លុះណាតែយើងបានស្គាល់តួអង្គយ៉ាងច្បាស់ជាមុនសិន។ ហេតុនេះយើងត្រូវតែចូលទៅក្នុងចិត្ត ចូលទៅក្នុងការគិតរបស់តួអង្គដើម្បីអោយតួអង្គរៀបរាប់ប្រាប់ពីការគិតរបស់គេចេញមក។ មានន័យថា យើងត្រូវគិតថារូបយើង(អ្នកនិពន្ធ)ជាតួអង្គនោះ១ តែម្តង។ បើកាន់តែស៊ីជំរៅប៉ុនណានោះអ្នកអានក៏កាន់តែយល់ដឹងពីតួអង្គច្រើនប៉ុននោះដែរ ។

**៥-ការសន្ទនា** (Dialogue)

យើងអាចបង្កើតរូបភាពតួអង្គអោយលេចធ្លោកាន់តែច្បាស់ឡើងបានតាមរយៈការសន្ទនា ដោយតួអង្គជាអ្នកសំដែងចេញតាមរយៈពាក្យសំដីរបស់គេផ្ទាល់ វីការប្រើកថាផ្ទាល់(Direct Speesh) ។ **ឧទាហរណ៍** យើងអាចប្រើកថាផ្ទាល់ដើម្បីបង្ហាញដល់អ្នកអានអោយដឹងថា តួអង្គនោះមកពីណាដោយការប្រើភាសាតាមតំបន់ដូចជា អោយតួអង្គនិយាយរដឹន (តួអង្គជាអ្នកខេត្តសៀមរាប) ។ល ។ ក្នុងការប្រើកថាផ្ទាល់នេះ យើងត្រូវផ្តោតលើហេតុផលពីរយ៉ាងគឺ ១.ផ្តល់ព័ត៌មានដល់អ្នកអាន (Give information to reader)២.ធ្វើអោយដំណើររឿងបន្តទៅមុខ (To move the story forward) ។ យើងក៏អាចប្រើ កថាមិនផ្ទាល់(Indirect Speec) បានដែរ ។ សរុបមក យើងអាចនឹងបង្កើតបុគ្គលិកលក្ខណៈ (Characterization) អោយ

www.elibraryofcambodia.org

ដល់តួអង្គបានលុះណាតែយើងប្រើវិធីតំណាលរឿងអោយអ្នកអានស្គាល់តួអង្គរបស់យើង ។ ប៉ុន្តែបើយើងប្រើវិធីតំណាលរឿងតែវិធីណាមួយដដែលៗនោះ វាមិនបានផលល្អទេ ។ ដូចនេះយើងត្រូវផ្លាស់វិធីតំណាលរឿងរហូតមួយចប់រឿង ។

ក្នុងពេលយើងសរសេរតំណាលរឿង យើងមិនត្រូវគិតថាកិច្ចការនោះ ជាតួនាទីរបស់អ្នកនិពន្ធឡើយ ព្រោះថាបើធ្វើក៏ព្រោះតែតួនាទី នោះយើងក៏មិនបានទទួលអារម្មណ៍សប្បាយជាមួយនឹងការសរសេររឿងទេ ។ ដូចនេះយើងត្រូវត្រៀមជាស្រេចនឹងចូលទៅក្នុងចិត្តរបស់តួអង្គអោយខាងតែបាន(ចូលតួ) ដ្បិតបើយើងធ្វើតាមទ្រឹស្តី នោះតួអង្គរបស់យើងប្រៀបបានទៅនឹងមនុស្សគ្មានវិញ្ញាណឡើយ ។ម្យ៉ាងទៀតបើយើងមិនយកចិត្តទុកដាក់លើការទទួលអារម្មណ៍របស់តួអង្គ ថាតើគេមានក្តីប្រាថ្នាបែបណា ឬមានរឿងពីអឌិតដែលធ្វើអោយគេមានបញ្ហាពិតមែនទេនោះ អ្នកអានរឿងដែលយើងសរសេរ ក៏នឹងទទួលអារម្មណ៍ដូចគ្នានេះដែរ ។

www.elibraryofcambodia.org

# គ្រោងរឿង

ការសរសេររឿងប្រលោមលោក ប្រៀបដូចជាការធ្វើដំនើរផ្លូវឆ្ងាយដែរ ។ បើសិនណាយើងមិនប្រាកដក្នុងចិត្តថា ផ្លូវមួយណាត្រូវទិសដៅដែលយើងត្រូវទៅទេនោះ យើងក៏អាចនឹងវង្វេងផ្លូវបាន ។ ថ្វីបើពេលខ្លះ ការវង្វេងផ្លូវអាចធ្វើអោយយើងមានអារម្មណ៍ថាប្លែកល្អម្យ៉ាងដែរ តែភាគច្រើនវាច្រើនតែធ្វើអោយយើងមិនសូវពេញចិត្ត ដោយសារមានការខាតបង់ពេលវេលាច្រើន ។

អ្នកខ្លះទទួលស្គាល់ថា គេបានខំចំណាយពេលសរសេររឿងអស់ជាច្រើនខែមកហើយ តែត្រូវបោះចោលទាំងអស់ទៅវិញ ដោយសារតែដើរខុសផ្លូវ ព្រោះតែមិនមានការប្រទាក់ក្រលាហេតុការណ៍នៅក្នុងផ្ទៃរឿង ។ យើងអាចនឹងប្រៀបប្រដូចគ្រោងរឿងទៅនឹងការចាក់អាវបានដែរ ។ បើមិនមានចន្លោះសំរាប់ប្រទាក់ក្រលាគ្នាទេ ទោះជាអ្នកចាក់អាវនោះមានថ្វីដៃល្អប៉ុនណាក៏ដោយ ក៏មិនអាចនឹងធ្វើអោយមើលទៅគួរអោយចាប់អារម្មណ៍បានដែរ ។

### គ្រោងរឿងជាអ្វី?

គ្រោងរឿងជាការចាត់រៀងលំដាប់ហេតុការណ៍ដែលកើតឡើងជាមួយនឹងតួអង្គក្នុងរឿង ដោយមានហេតុការណ៍ដែលប្រែប្រួលរបស់រឿងរឺតួអង្គ ហើយនៅទីបញ្ចប់មានការសមនឹងចិត្តរបស់អ្នកអាន នៅវគ្គបញ្ចប់របស់រឿង ។

គ្រោងរឿង ជាយន្តការនៃការដំនើររឿងឆ្ពោះទៅកាន់ទីបញ្ចប់នៃរឿង ។

www.elibraryofcambodia.org

គ្រោងរឿង ជាការដំណើររឿងដែលប្រកបដោយការប្រែប្រួល ហើយការប្រែប្រួលដ៏សំខាន់របស់ប្រលោមលោកកើតពីបញ្ហាវិទំនាស់ ។ បើយើងសរសេររឿងមួយ ដោយអោយអ្វីៗគ្រប់យ៉ាងដែលកើតឡើង ជំរុញអោយតួឯកជួបតែនឹងសេចក្តីសុខនោះ មិនយូរប៉ុន្មានទេ អ្នកអានក៏ធុញទ្រាន់មិនខាន ។ ម្យ៉ាងវិញទៀត បើការប្រែប្រួលសំខាន់របស់រឿង មិនបានបង្កើតបញ្ហាអោយដល់តួឯក អ្នកអានក៏អស់ចំណាប់អារម្មណ៍ ព្រោះតែមិនមានរឿងអោយតួអង្គត្រូវសំរេចចិត្តទៀត ។

**មធ្យោបាយក្នុងការបង្កើតគ្រោងរឿង**

ការគិតដំណើររឿងក្នុងប្រលោមលោក យើងគួរចាប់ផ្តើមគិតពីតួអង្គជាមុន ថា**តើតួអង្គនោះជានរណា? មកពីណា? មានប្រវត្តិជីវិតយ៉ាងណា? ហើយយើងគួរ [illegible]ទៅទីណា? ជួបហេតុការណ៍អ្វីខ្លះ? លទ្ធផលដែលទទួលបានយ៉ាងណាដែរ?**

វិធីមួយទៀតដែលជាវិធីល្អបំផុតក្នុងការបង្កើតគ្រោងរឿង គឺអ្នកនិពន្ធគិតពីការគិតរបស់តួអង្គ ។ **ការគិតនោះ ជាបច្ច័យដែលធ្វើអោយតួអង្គធ្វើអ្វីមួយអោយកើតជាហេតុការណ៍ប្រព្រឹត្តទៅក្នុងដំណើររឿង ។**

ក្នុងការបង្កើតគ្រោងរឿង បើយើងអោយតួឯកទទួលបានជោគជ័យ សមប្រាថ្នាតាំងពីដំបូងភ្លាមៗនោះ មានន័យថា យើងគ្មានរឿងអ្វីនឹងសរសេរទៀតទេ។ ដូចនេះយើងត្រូវរៀបគ្រោងរឿងអោយមានហេតុការណ៍ដែលនឹងធ្វើអោយក្តីប្រាថ្នារបស់តួឯកត្រូវជួបប្រទះនឹងការរារាំង ដែលអាចបណ្តាលមកពីតួអង្គដទៃ រឺមកពីហេតុការណ៍ដែលមិនរលូន ។

មុនចាប់ផ្តើមសរសេររឿង យើងគួរមានគំរោងគ្រោងរឿងត្រួសៗក្នុងចិត្ត

www.elibraryofcambodia.org

របស់យើងជាមុនសិន ដើម្បីជួយយើងក្នុងឋានៈជាអ្នកនិពន្ធអោយអាចរិះគិតជ្រើសយកមធ្យោបាយដំនើររឿងណាមួយបាន។

**គ្រោងរឿងគួរមានធាតុផ្សំជាមូលដ្ឋាន ដូចតទៅនេះ :**

១-តួអង្គ(តួអង្គដែលអ្នកអានហួងហែង)(Character)

២-ទំនាស់ (Conflict)

៣-ភាពស្មុគស្មាញ (Complication)

៤-ទំនាស់ដល់ចំនុចកំពូល(Climax or Crisis)

៥-ដំណោះស្រាយ (Resolution)




www.elibraryofcambodia.org

**ធាតុផ្សំទី១-តួអង្គ (Character)**

យើងត្រូវមានតួឯក(Protagonist)ដែលអ្នកអានហួងហែង ជួយព្រួយ ជួយភ័យ ជួយអរ ជួយបារម្ភជំនួសតួអង្គ។ ទាំងនេះគឺជាតួនាទីរបស់អ្នកនិពន្ធ ដែលជាអ្នកបង្កើតតួអង្គធ្វើឱ្យអ្នកអានពេញចិត្តនិងអាណិតស្រលាញ់តួអង្គ។ ទោះជាយើងជ្រើសរើសសរសេរអោយតួឯកជាឃាតករ រឺជាជនពាលក្តី យើងក៏ត្រូវតែធ្វើអោយអ្នកអានចាប់អារម្មណ៍ បើយចង់ដឹងរឿងរ៉ាវរបស់គេ ទោះជាអ្នកអានមិនចូលចិត្តតួអង្គនោះក៏ដោយ។ យើងត្រូវធ្វើអោយអ្នកអានស្គាល់តួអង្គ ដោយផ្តល់ព័ត៌មានលំអិតពីបុគ្គលិកលក្ខណៈ និងក្តីប្រាថ្នារបស់តួអង្គដល់អ្នកអាន ដើម្បីអោយគេបានស្គាល់តួអង្គបានច្បាស់។

តួកាចរឺតួចិត្តអាក្រក់(Antagonist or Villian)ជាតួអង្គសំខាន់រងបន្ទាប់ពីតួឯក ហើយច្រើនតែជាតួអង្គដែលមានទំនាស់ជាមួយតួឯក រឺក៏ជាអ្នករារាំងតួឯកមិនអោយសំរេចបំណង។ ថ្វីបើអ្វីដែលមករារាំងតួឯកមិនអោយសមប្រាថ្នាអាចជាអ្វីដែលមិនមែនជាមនុស្ស ដូចជា ទឹកជំនន់គ្រោះថ្នាក់។ល។ ប៉ុន្តែវាក៏មិនមានអ្វីដែលជាបញ្ហាជំទាស់នឹងតួអង្គខ្លាំងជាងមនុស្សនោះទេ ហើយក៏គ្មានអ្វីដែលអាចទាក់ទាញចិត្តអ្នកអានបាន ដូចទំនាស់រវាងមនុស្សនឹងមនុស្សបានទេ។ តួអង្គដែលជាតួកាចក្នុងរឿង គួរតែពូកែស្មើនឹងតួឯក ហើយរឿងដែលល្អមើលច្រើនតែមានតួឯកនិងតួកាចអាចទប់ទល់គ្នាបាន ព្រោះតួកាចដែលអាក្រក់ពិតអាចនឹងធ្វើអោយតួឯកមានបញ្ហាកាន់តែខ្លាំងឡើង ច្រើនល្មមអាចនឹងធ្វើអោយអ្នកអានចង់តាមដានជួយព្រួយភ័យជួយឈឺចាប់ជំនួសតួឯក រហូតមួយចប់រឿង។

www.elibraryofcambodia.org

**តើតួអង្គដែលជាគូបដិបក្ខជាមួយនឹងតួឯកត្រូវតែជាតួកាចជានិច្ចឬ?**

តួអង្គដែលជាគូបដិបក្ខជាមួយនឹងតួឯក មិនចាំបាច់ជាតួកាចជានិច្ចនោះទេ គឺគ្រាន់តែតួអង្គនោះអាចមានក្តីប្រាថ្នាដែលមិនស្របនឹងក្តីប្រាថ្នារបស់តួឯកប៉ុណ្ណោះ ដូចជា បើយើងសរសេរអោយតួឯកស្រីជាមេម៉ាយប្តីស្លាប់ ហើយនាងទៅស្រលាញ់ប្តីរបស់មិត្តជិតស្និទ្ធម្នាក់ ក៏មិនគួរមានន័យថា មិត្តរបស់នាងជាតួកាចក្នុងរឿងទេ ។ មួយវិញទៀតបើយើងសរសេររឿងក្នុងការិយាល័យដែលតួឯកធ្វើការមានគូប្រជែងដែលខំព្យាយាមដណ្តើមតំណែងជាមួយតួឯក តួអង្គនោះក៏មិនចាំបាច់ជាតួកាចដែរ ដោយគ្រាន់តែគេមានក្តីប្រាថ្នាអ្វីមួយដូចគ្នាតែប៉ុណ្ណោះ ។

**ធាតុផ្សំទី២-ទំនាស់** (Conflict)

យើងអាចនឹងសរសេររឿងទៅបានលុះណាតែមានទំនាស់ ។ ដូចនេះទំនាស់ **គឺជាធាតុផ្សំមូលដ្ឋានរបស់គ្រោងរឿង ព្រោះបើគ្មានទំនាស់ទេ ក៏គ្មានរឿងដែរ ។** ប៉ុន្តែតាមពិតទៅទំនាស់មិនមែនជារឿងល្អទេ ក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្សយើង មិនសូវជាមាននរណាចង់ប្រឈមមុខនឹងទំនាស់ឡើយ ។ ពេលណាមានមនុស្សឈ្លោះប្រកែកគ្នាសំឡេងខ្លាំង អ្នកដែលនៅក្បែរក៏បែរងាកទៅមើលយ៉ាងយកចិត្តទុកដាក់តែមួយសន្ទុះក្រោយមកក៏ដើរចេញទៅវិញ ។

ប៉ុន្តែក្នុងការសរសេរគ្រោងរឿង យើងចាំបាច់ត្រូវបង្កើតទំនាស់ ។ ពោលគឺតួឯកត្រូវតែប្រឈមនឹងទំនាស់ ដែលច្រើនតែកើតចេញពីតួអង្គដទៃ ។ ជាពិសេសគឺតួអង្គដែលជាអ្នកមករារាំងក្តីប្រាថ្នារបស់តួឯកនោះ ។

ទំនាស់គឺជាបញ្ហាដែលតួឯកត្រូវដោះស្រាយអោយខាងតែបាន ដើម្បីឈ្នះ

www.elibraryofcambodia.org

ហើយបានទទួលនូវអ្វីដែលខ្លួនប្រាថ្នា ។

យើងគួរបង្កើតគ្រោងរឿងគោល ដោយធ្វើអោយតួអង្គជួបនឹងស្ថានការណ៍ វិបត្តិដែលគេទ្រាំមិនបាន ។ បន្ទាប់មកបង្កើតគ្រោងរឿងតូចៗច្រើនបែបទៀតដើម្បី ធ្វើអោយស្ថានការណ៍កាន់តែស្មុគស្មាញឡើង ដែលជាការឆ្ពោះទៅកាន់វគ្គបញ្ចប់ ។ ជាពិសេសយើងត្រូវរំពឹងគិតជានិច្ចថា រឿងប្រលោមលោក វាទាក់ទងនឹងអ្វីដែល គួរតែនឹងកើតឡើង ច្រើនជាងអ្វីដែលបានកើតឡើងរួចទៅហើយ ។

យើងគួរចងចាំថាគ្រោងរឿងដែលល្អ គឺគ្រោងរឿងដែលមានហេតុការណ៍ ប្រព្រឹត្តទៅ ដោយតួអង្គជាអ្នកដឹកនាំ ។ ថ្វីបើយើងជាអ្នកបង្កើតស្ថានការណ៍អោយ តួអង្គបែបណាក៏ដោយ ក៏តួអង្គនៅតែជាអ្នកនាំផ្លូវឆ្ពោះទៅកាន់ចំនុចបញ្ចប់នៃរឿង ដោយខ្លួនឯង ។ ទាំងនេះ គឺជាសម្ព័ន្ធភាពរវាងតួអង្គនឹងគ្រោងរឿង ។

មួយវិញទៀតយើងត្រូវដឹងថាបញ្ហាវិទំនាស់ណាដែលងាយនឹងដោះស្រាយ គឺជាបញ្ហាដែលងាយនឹងភ្លេចទៅវិញដែរ ។ ចំនែកឯទំនាស់ដែលសាំញុាំ វាធ្វើអោយ យើងពិបាកនឹងរកផ្លូវដោះស្រាយ តែវាក៏អាចបន្សល់ទុកក្នុងការចងចាំក្នុងខួរក្បាល របស់អ្នកអានបានយូរ និងធ្វើអោយអ្នកអានចង់ដឹងចង់តាមដានផងដែរ ។

**ធាតុផ្សំទី៣-ភាពស្មុគស្មាញ** (Complication)

ភាពស្មុគស្មាញនៃផ្ទៃរឿងអាចមានទំហំប៉ុនណាអាស្រ័យលើរឿងវែងរឺខ្លី ។ ពោលគឺ បើរឿងវែងក៏មានភាពស្មុគស្មាញច្រើនតាមនោះទៅដែរ ។ ហេតុនេះយើង ជាអ្នកនិពន្ធត្រូវរំពឹងគិតដល់គ្រោងរឿងរង(Subplot) របស់រឿងផងក្នុងការបង្កើត គ្រោងរឿង ។

www.elibraryofcambodia.org

ប៉ុន្តែរាល់គ្រោងរឿងរងត្រូវមានចំណែករួមក្នុងការបង្កើតហេតុការណ៍ និងមានការប្រែប្រួលក្នុងគ្រោងរឿងគោលផង ។ បើសិនគ្រោងរឿងរងនោះអាចកាត់ចោលដោយមិនមានផលប៉ះពាល់ដល់ការប្រែប្រួលរបស់រឿងទេ នោះមានន័យថាគ្រោងរឿងរងនោះមិនគួរនឹងមានក្នុងរឿងឡើយ ។

យើងអាចនឹងបង្កើតភាពស្មុគស្មាញបាន ដោយការប្រើអ្នកតំណាលរឿងច្រើននាក់ (Unlimited Point of View) ព្រោះគេប្រើការតំណាលរឿងពីមនុស្សច្រើននាក់ នោះមនុស្សម្នាក់ៗតែង[illegible]ពីគ្នា ហើយក៏បង្កើតអោយមានទំនាស់ មានបញ្ហាផ្សេងពីគ្នា [illegible]របស់គ្រោងរឿងរងផ្សេងពីគ្នា រឺខុសពីគ្រោងរឿងគោល ។

គ្រោងរឿងរងធ្វើអោយប្រលោមលោកកាន់តែវែងឡើង រឺធ្វើអោយអ្នកនិពន្ធមានរឿងសរសេរកាន់តែច្រើនឡើង ។ ជាពិសេសគ្រោងរឿងរងអាចនឹងជួយបង្កើតភាពស្មុគស្មាញរបស់រឿងអោយកាន់តែច្រើនឡើងផងដែរ ។

**ធាតុផ្សំទី៤-ទំនាស់ដល់កំពូល** (Climax or Crisis)

រឿងដែលរល្ងេនប្រាសចាកបញ្ហានិងទំនាស់ផ្សេងៗ វាមិនសូវជាល្អមើលទេ ព្រោះអ្នកអានមិនមានឱកាសបានរួមចំនែកជួយព្រួយ ជួយភ័យ ជួយខឹង ជួយអរជាមួយនឹងតួអង្គឡើយ ។

ក្នុងដំនើររឿងត្រូវមានតួអង្គណាមួយប្រាថ្នាចង់បានអ្វី ហើយរឿងរ៉ាវប្រព្រឹត្តទៅព្រោះតែចង់បានដូចបំនងប្រាថ្នារបស់តួអង្គនោះ ។ រឿងខ្លះជាការប្រាថ្នាចង់មានជីវិតរស់នៅតទៅទៀត រឿងខ្លះប្រាថ្នាចង់បានលុយកាក់មាសប្រាក់ រឿង

www.elibraryofcambodia.org

ខ្លះប្រាថ្នាសេចក្តីស្នេហា។ រីឯរឿងខ្លះទៀតប្រាថ្នាចង់អោយស្ថានការណ៍ត្រលប់មកប្រក្រតីវិញ។ ប៉ុន្តែមានតួអង្គខ្លះសមបំនង ខ្លះក៏មិនសមបំនង ទោះជាព្យាយាមក្តី។ ពេលនេះវិបត្តិកាន់តែខ្លាំងទៅៗ រហូតដល់ចំនុចកំពូល...

**ធាតុផ្សំទី៥-ដំណោះស្រាយ** (Resolution)

វគ្គបញ្ចប់នៃរឿង គឺជាការស្រាយបញ្ហារបស់តួឯកនិងរបស់រឿង។

ការស្រាយបញ្ហា សំដៅដល់រឿងសំខាន់ៗគ្រប់រឿងរ៉ាវក្នុងប្រលោមលោកមកដល់ចំណុចបញ្ចប់ ហើយតួឯកក្នុងរឿងមិនមានផ្លូវជ្រើសរើសផ្សេងទៀតទេ។

ប្រលោមលោកខ្លះបញ្ចប់ដោយសោកនាដកម្ម(Tragedy)គឺបញ្ចប់ដោយមរណភាពរបស់តួអង្គ។ មានន័យថាតួអង្គដែលត្រូវស្លាប់មិនអាចនឹងជ្រើសរើសផ្លូវផ្សេងទៀតបាន(អ្នកនិពន្ធជាអ្នកសំរេចអោយតួអង្គនោះស្លាប់)។ ប៉ុន្តែបើសិនយើងបង្កើតគ្រោងរឿងជាសោកនាដកម្ម យើងមិនត្រូវប្រើការស្លាប់របស់តួអង្គជាការជ្រើសរើសបែបងាយៗរបស់អ្នកនិពន្ធនោះទេ(មានន័យថា ពេលសរសេរៗទៅ មិនដឹងជាបញ្ចប់រឿងយ៉ាងណា ក៏អោយតួឯកស្លាប់តែម្តងទៅ)។

ប្រលោមលោកខ្លះទៀត បញ្ចប់រឿងដោយមានក្តីសុខ (Happy Ending) ព្រោះតួឯកបានជួបស្ត្រីដែលខ្លួនពេញចិត្ត...

ទោះជាយ៉ាងណាក្តីអ្វីមួយដែលអ្នកអានប្រលោមលោកចង់បានពីការអានគឺដើម្បីមានការយល់ដឹងអំពីជីវិតបានកាន់តែច្បាស់ឡើង។ ជាពិសេស គឺរឿងដែលទាក់ទងនឹងអ្វីដែលធ្វើអោយកើតមានភាពតក់ស្លុត រន្ធត់ចិត្ត ការឈឺចាប់ រឺអ្វីដែលអ្នកអានមិនធ្លាប់បានយល់ដឹងពីមុនមក។

www.elibraryofcambodia.org

# ការតំណាលតាមទស្សនៈ

ការជ្រើសរើសអ្នកតំណាលរឿង រឺការតំណាលតាមទស្សនៈរបស់អ្នកណា ជាអ្វីដែលសំខាន់បំផុត ក្នុងការសរសេររឿងប្រលោមលោករបស់យើង ។ ហេតុនេះ មុនពេលដែលយើងជ្រើសរើសប្រើការតំណាលរឿងតាមទស្សនៈ(Point of View) ណាមួយនោះ យើងគួរតែរិះគិតថាអ្នកតំណាលរឿង(Narrator)ជាមនុស្សដែលគួរ អោយអ្នកជឿទុកចិត្តបានដែររឺទេ ។ (**Point of View-** គឺជាការតំណាលតាម ទស្សនៈរបស់អ្នកនិពន្ធ រឺរបស់តួអង្គដែលកំពុងតំណាលរឿង ។)

**ឧទាហរណ៍** បើយើងអោយតួអង្គមួយដែលនៅទីបញ្ចប់នៃរឿងក្លាយជា មនុស្សឆ្កួតជាអ្នកតំណាលរឿង អោយមនុស្សចាស់តែជាមនុស្សល្ងង់ រឺប្រព្រឹត្តខ្លួន ផ្តេសផ្តាសជាអ្នកតំណាលរឿង រឺមួយក៏អោយតួអង្គមួយនៅក្មេងដែលពុំទាន់ដឹងក្តី តំណាលរឿងរបស់ម្តាយខ្លួនកាលពីគេពុំទាន់កើតនៅឡើយ នោះអ្នកអានមុខជានឹង មានអារម្មណ៍ធុញទ្រាន់ ហើយឈប់អានជាមិនខាន ។

ដូចនេះយើងត្រូវជ្រើសរើសយកតួអង្គណា ដែលមានទំនាក់ទំនងល្អជាមួយនឹង អ្នកអាន និងអាចទាក់ទាញចំនាប់អារម្មណ៍អ្នកអានបាន អោយធ្វើជាអ្នកតំណាល រឿង ទើបល្អ ។

ប៉ុន្តែ**ការតំណាលរឿងតាមទស្សនៈ**ច្រើនតែត្រូវអ្នកអានមើលរំលង ព្រោះ អ្នកអានច្រើនតែមើលធាតុផ្សំដទៃៗទៀតច្រើនជាង ដូចជា យើងច្រើនតែបានលឺ

www.elibraryofcambodia.org

អ្នកអាននិយាយថា "តួអង្គក្នុងរឿងនេះល្អណាស់" "អ្នកនិពន្ធពូកែមែន" តែយើងមិនដែលបានលឺអ្នកអាននិយាយថា អ្នកនិពន្ធប្រើការតំណាលតាមទស្សនៈ(Point of View)ល្អបំផុត ម្តងណាសោះឡើយ ។

**ទំរង់ជាមូលដ្ឋាននៃ** Point of View **អាចចែកជា ៣ បែប :**

-បុរសទីមួយ (First Person Point of View )

-បុរសទីពីរ (Second Person Point of View )

-បុរសទីបី (Third Person Point of View )

**១-តំណាលរឿងតាមទស្សនៈបុរសទីមួយ** ( First Person Point of View)

ការប្រើបុរសទីមួយជាអ្នកតំណាលរឿង គឺការតំណាលដោយប្រើការគិត និងទស្សនៈរបស់តួអង្គណាមួយ ដោយអោយតួអង្គនោះជាអ្នកតំណាល ដែលអាចជាតួឯក(Protagonist)នៃរឿង ជាតួរង រឺជាតួចិត្តអាក្រក់(Antagonist)របស់យើងក៏បាន ។

កាលបើប្រើបុរសទីមួយ(ខ្ញុំ)ជាអ្នកតំណាល ភាពច្បាស់លាស់នៃអារម្មណ៍ ការទទួលអារម្មណ៍ ច្រើនតែជ្រៅជាងការប្រើបុរសទីបីជាអ្នកតំណាល ។ ប៉ុន្តែក៏មិនមែនមានន័យថា ប្រលោមលោកគ្រប់រឿង **ត្រូវប្រើ រឺគួរប្រើ** បុរសទីមួយជានិច្ចនោះទេ ព្រោះការតំណាលរឿងតាមទស្សនៈរឺតាមខ្សែភ្នែករបស់បុរសទីមួយមានដែនកំនត់ផងដែរ គឺយើងមិនអាចនឹងតំណាលរឿងដែលបុរសទីមួយមិនដឹងអោយដល់អ្នកអានបានទេ។ ការប្រើបុរសទីមួយអ្នកនិពន្ធអាចតំណាលបានត្រឹមតែការគិត និងការទទួលអារម្មណ៍របស់តួអង្គមួយនោះតែប៉ុននោះ ។

www.elibraryofcambodia.org

មួយវិញទៀតចំនុចខ្សោយរបស់បុរសទីមួយ គឺវាមានការលំបាកក្នុងការសរសេរតំណាលឆ្លងកាត់តាមខ្សែភ្នែកបុរសទីមួយ( **ខ្ញុំ** ) ថា ខ្ញុំជាមនុស្សល្អ ពូកែ អង់អាចក្លាយបាន ឈ្លាសវៃ ស្អាត វីសង្ហាបានណាស់ ព្រោះទោះបីជា " **ខ្ញុំ** " ដឹងពិតក៏មិនដឹងថានឹងប្រាប់អ្នកអានយ៉ាងដូចម្តេចទេ ដើម្បីកុំអោយអ្នកអានយល់ថានេះជាការអួតនោះ ។

**២-តំណាលរឿងតាមទស្សនៈបុរសទីពីរ** ( Second Person Point of View )

ការតំណាលរឿងតាមទស្សនៈបុរសទីពីរអាចនិយាយបានថា ស្ទើរតែគ្មានប្រើសោះក្នុងការសរសេររឿងប្រលោមលោក ។ យើងមិនគួរយក **ការតំណាលរឿងតាមទស្សនៈបុរសទីពីរ** មកប្រើ ក្នុងការសរសេររឿងប្រលោមលោកទេ ព្រោះវាអាចធ្វើអោយអ្នកអានមានអារម្មណ៍ឆាប់ទើ្បយណាយធុញថប់បាន ។ម្យ៉ាងទៀតបើយើងប្រើការតំណាលរឿងតាមទស្សនៈបុរសទីពីរ( **អ្នក** ) មានន័យថា យើងត្រូវសរសេរពីអ្នកអាន ។

**៣-តំណាលរឿងតាមទស្សនៈបុរសទីបី** ( Third Person Point of View )

ការតំណាលរឿងតាមទស្សនៈបុរសទី៣ យើងអាចចែកជាពីរបែបគឺ ការតំណាលរឿងតាមទស្សនៈបុរសទីបីបែបកំនត់ការយល់ដឹង (Limited Omniscient) និងការតំណាលរឿងតាមទស្សនៈបុរសទីបី បែបដឹងសព្វ (Omniscient )

**ក.ការតំណាលរឿងតាមទស្សនៈបុរសទីបីបែបកំនត់ការយល់ដឹង**

ការតំណាលរឿងបែបនេះជាការតំណាលតាមទស្សនៈរបស់តួអង្គណាមួយដែលកំពុងធ្វើសកម្មភាព ហើយច្រើនតែអាចបង្កើតភាពស៊ីជំរៅជិតស្និទ្ធជាមួយនឹង

www.elibraryofcambodia.org

អ្នកអានបានច្រើនជាងបែបដឹងសព្វ ព្រោះតួអង្គដែលយើងប្រើជាអ្នកតំណាលនោះ គឺជាអ្នកបង្ហាញសកម្មភាព ការមានអារម្មណ៍ ការទទួលអារម្មណ៍ និងការប្រើពាក្យសំដី ឆ្លងកាត់តាមទស្សនៈរបស់គេតែម្នាក់ឯង ។

**ខ.ការតំណាលរឿងតាមទស្សនៈបុរសទីបីបែបដឹងសព្វ**

ក្នុងការតំណាលរឿងបែបនេះ អ្នកនិពន្ធត្រូវប្រកបទៅដោយសព្វញ្ញុភាព **(សប់-ព័ញ-ញុ-ភាព)** គឺអាចមើលឃើញការគិត ការទទួលអារម្មណ៍ និងសកម្មភាពរបស់គ្រប់ៗគ្នា។ ពោលគឺ អ្នកនិពន្ធដឹងគ្រប់យ៉ាង គ្រប់ទីកន្លែង គ្រប់ពេលវេលាទាំងពីអតីតរឺអនាគត ។

**គួរជ្រើសយកការតំណាលតាមទស្សនៈ** (Point of View) **មួយណាទើបល្អ**

មុនពេលចាប់ផ្តើមសរសេររឿង យើងគួរសំរេចចិត្តថាអោយនរណាជាអ្នកតំណាលរឿង(ប្រើ Point of View មួយណា) ។ បើយើងនឹងតំណាលរឿងឆ្លងតាមទស្សនៈតួអង្គមួយណា ដំបូងបង្អស់យើងត្រូវសួរខ្លួនឯងថា តើតួអង្គមួយណានោះអាចនឹងបង្ហាញទស្សនៈដែលគួរអោយចាប់អារម្មណ៍បំផុត? តើតួអង្គមួយណាមានគោលគំនិតច្រើនបំផុត? តួអង្គណាដែលអាចធ្វើអោយការតំណាលរឿងតាមទស្សនៈរបស់គេមានរសជាតិច្រើនបំផុត? ពោលគឺវាអាចធ្វើអោយប្រលោមលោកល្អមើល និងគួរអោយចង់តាមដានបំផុត ។

ពេលយើងជ្រើសរើសតួអង្គដែលជាអ្នកតំណាលរឿងបានហើយ យើងគួរប្រយ័ត្នប្រយែងក្នុងការសរសេរតំណាល ព្រោះថ្វីបើអ្នកតំណាលដែលជាបុរសទី១ មានចំនុចល្អដែលអាចតំនាលបានស៊ីជំរៅ តែក៏អាចមានដែនកំនត់ដែរ ។ ពោលគឺ

www.elibraryofcambodia.org

ធ្វើយ៉ាងណាកុំអោយជ្រុលសហួសពេក ។

ប្រសិនបើរឿងនោះជាប្រលោមលោករឿងដំបូងរបស់យើង យើងគួរប្រើបុរសទី៣ ទើបងាយស្រួលជាង ព្រោះអាចសរសេរអោយបានទាំងស៊ីជំរៅជិតស្និទ្ធនឹងតួអង្គ និងឃ្លាតឆ្ងាយពីតួអង្គបានផងដែរ ។ ប៉ុន្តែតាមពិតទៅពេលយើងសរសេររឿងមិនមាននរណាអាចប្រាប់យើងបានទេថា យើងគួរជ្រើសរើសការតំណាលតាមទស្សនៈ(PointogView)បែបណានោះ ។ ពោលគឺមានតែខ្លួនយើងម្នាក់តែប៉ុននោះដែលអាចនឹងឆ្លើយចំពោះសំនួររបស់ខ្លួនឯងបាន ។ ទោះជាយ៉ាងណាក្តីយើងត្រូវធ្វើអោយតួអង្គណាមួយនោះ ជាអ្នកជំរុញដំនើររឿង ។

ប្រលោមលោកខ្លះច្រើនអោយតួឯកជាអ្នកតំណាលរឿង ។ ប៉ុន្តែយើងមិនត្រូវភ្លេចថា តួឯកក្នុងរឿង គឺជាតួអង្គដែលយើងជាអ្នកជ្រើសរើស ។ ដូចនេះយើងក៏មានសិទ្ធិជ្រើសអោយតួអង្គដទៃ ធ្វើជាអ្នកតំណាលរឿងក៏អាចបានដែរ ។

សរុបមកយើងគួរតែសាកល្បងជ្រើសតួអង្គអោយបានច្រើនតួ ព្រោះការជ្រើសប្រើការតំណាលតាមទស្សនៈណាមួយនោះ វាអាស្រ័យលើយើងជាអ្នកជ្រើសយកដោយខ្លួនឯង ។ ប្រការដែលសំខាន់ គឺធ្វើយ៉ាងណាអោយអ្នកអានចង់តាមដានអានរឿងរបស់យើង ។

www.elibraryofcambodia.org

## ការរៀបចំឆាក

ថ្វីបើប្រលោមលោកជារឿងប្រឌិត(Fiction) តែយើងចាំបាច់ត្រូវតែស្គាល់ទីកន្លែង និងពេលវេលារបស់រឿងដែលយើងសរសេរដូចគ្នានឹងអ្នកសរសេរឯកសារប្រវត្តិសាស្ត្រដែរ ។ ដូចនេះអ្នកសរសេរប្រលោមលោកត្រូវប្រើឆាក(Sitting) ដោយសរសេរតាមសមត្ថភាពនិងចំនេះដឹងប្រហាក់ប្រហែលគ្នានឹងអ្នកសរសេរឯកសារឬសរសេរប្រវត្តិសាស្ត្រដែរ ។

ហេតុនេះពេលយើងសរសេររឿង យើងចាំបាច់ត្រូវប្រមូលព័ត៌មានលំអិតដូចជា ប្រវត្តិដើម និងស្ថានភាពពិតនៃទីកន្លែង ដែលយើងនឹងលើកយកមកធ្វើជាឆាករបស់រឿង ។ ការធ្វើដូចនេះអ្នកអានអាចនឹងទទួលបានទាំងការអានកំសាន្ត រួមទាំងបានចំនេះដឹងផង ព្រោះឆាកក្នុងប្រលោមលោក វាអាចជាចំណែកមួយនៃអតីតកាល រឺជាចំណែកមួយនៃប្រវត្តិសាស្ត្រ ។

មធ្យោបាយមួយដែលអាចនឹងជួយយើងបាន គឺការធ្វើដំនើរទៅកំសាន្តទៅទីកន្លែងពិតដែលយើងលើកយកមកធ្វើជាឆាករបស់រឿង ទៅជួបសំណេះសំណាលចាស់ៗដែលរស់នៅទីនោះ រឺស្វែងយល់ពីមូលដ្ឋាននោះតាមរយៈការអានសៀវភៅ ។ ជួនកាលការជួបសំណេះសំណាលជាមួយអ្នកដែលរស់នៅក្នុងមូលដ្ឋាននោះ អាចនឹងធ្វើអោយយើងយល់ដឹងពីហេតុការណ៍ដែលយើងមិនធ្លាប់បានដឹង ហើយធ្វើអោយយើងទទួលអារម្មណ៍ថា យើងបានស្គាល់ទីនោះ( ឆាក) កាន់តែច្បាស់ឡើង ។

www.elibraryofcambodia.org

ការរៀបចំឆាកអាចប្រៀបបានទៅនឹងការដាំដើមឈើដែរ ។ បើយើងចង់ដាំដើមឈើអោយល្អ នោះយើងក៏ត្រូវរកដីដែលមានជីជាតិល្អ ទើបដើមឈើអាចនឹងចាក់ឫសចូលបានជ្រៅ និងអាចស្រូបយកជីជាតិពីដីនោះបាន ។

**គួររៀបចំឆាកយ៉ាងដូចម្តេច?**

វិធីដែលល្អបំផុតក្នុងការរៀបចំឆាក គឺពណ៌នាព្រមជាមួយនឹងសកម្មភាពរបស់តួអង្គម្តងបន្តិចៗ ។

ឧបមាថា តួអង្គរបស់យើងជាវេជ្ជបណ្ឌិតម្នាក់ ។ គេដើរចូលទៅក្នុងបន្ទប់ធ្វើការ ។ ពេលនោះយើងអាចនឹងប្រាប់អោយអ្នកអានមើលឃើញតាមរយៈប្រសាទណាមួយ( ក្នុងចំណោមប្រសាទទាំង៥) របស់គេ ដូចជា ពណ៌នាពីក្លិន សំឡេង រឺរូបភាពរបស់មន្ទីរពេទ្យ ។ បន្ទាប់មកយើងនាំគ្រូពេទ្យ( តួអង្គ) នោះ ដើរកាត់ហ្វូងមនុស្សម្នា ព្រមទាំងពណ៌នាពីការគិតរបស់គេ ដែលមានចំពោះបន្ទប់ណាមួយ...

យើងត្រូវនាំអ្នកអានចូលឆ្ពោះទៅកាន់ទីកន្លែង( ឆាក) ដែលអ្នកអានអាចមើលឃើញរូបភាពក្នុងមនោវិញ្ញាណរបស់គេផ្ទាល់បាន ។ នេះជាអ្វីដែលសំខាន់បំផុតដែលអ្នកនិពន្ធត្រូវជ្រើសយកយ៉ាងផ្ចិតផ្ចង់ ។

www.elibraryofcambodia.org

# ការបញ្ចប់រឿង

សាកល្បងនឹកគិតដល់រឿងប្រលោមលោកដែលអ្នកធ្លាប់បានអាន រឺរឿងភាគតាមកញ្ចក់ទូរទស្សន៍ និងភាពយន្តដែលអ្នកធ្លាប់បានទស្សនា ហើយសួរខ្លួនឯងថា តើរឿងទាំងនោះមានអ្វីដែលធ្វើអោយអ្នកមិនអាចបំភ្លេចរឿងនោះបាន? តើមានអ្វីដែលធ្វើអោយអ្នកស្តាយលុយ រឺស្តាយពេលវេលា?...

ប្រសិនណាបើយើងក្នុងនាមជាអ្នកនិពន្ធបានបំពេញការងាររបស់ខ្លួនយ៉ាងល្អហើយ នោះអ្នកអានអាចនឹងទទួលអារម្មណ៍សោកស្តាយពេលបានអានរឿងរបស់យើងមកជិតដល់ទីបញ្ចប់នៃរឿងនេះ ។ ប៉ុន្តែជួនកាលអ្នកនិពន្ធខ្លះខ្វះការអត់ធ្មត់ក៏ប្រញាប់បញ្ចប់រឿងលឿនហួសពេក ដូចជា រឿងរ៉ាវបានមកដល់ចំនុចដែលអន្ទងចិត្តអ្នកអាន ក៏បញ្ចប់រឿងភ្លាមៗតែម្តង ដោយពុំបានទុកឱកាសអោយអ្នកអានបានជ្រួតជ្រាបនិងសំរួលអារម្មណ៍ខ្លះសិនឡើយ ។ (ការបញ្ចប់បែបនេះភាគច្រើន គឺជាប្រលោមលោកផ្នែកស៊ើបអង្កេត ។)

ថ្វីបើយើងមានអារម្មណ៍ថាសរសេររឿងអោយឆាប់ចប់ តែយើងមិនគួរប្រញាប់ប្រញាល់ហួសពេកទេ ព្រោះគ្រប់ៗវគ្គនៃរឿងរមែងមានចំនុចសំខាន់ៗដែលយើងត្រូវទុកពេលវេលាអោយអ្នកអានបានរិះគិតសិន ។ ជាពិសេសយើងគួរធ្វើយ៉ាងណាអោយពេលដែលអ្នកអានបានអានចប់ បិទសៀវភៅ ហើយអ្នកអាននោះតាំងចិត្តរង់ចាំអានរឿងក្រោយរបស់យើងទៀត ។

ទោះជាយ៉ាងណាក្តី យើងមិនត្រូវភ្លេចគិតថា អ្នកអានកំពុងតែចង់ដឹងថា

www.elibraryofcambodia.org

តួអង្គក្នុងរឿង ក្រោយពីគេបានឆ្លងកាត់វិបត្តិនោះហើយ តើគេទៅជាយ៉ាងណា? ប៉ុន្តែទោះបីជាយើងមិនអាចនឹងប្រាប់អ្នកអានថា តួអង្គទាំងអស់នោះនឹងទៅជាយ៉ាងណា មានរឿងអ្វីកើតឡើងជាមួយនរណាខ្លះ តែយើងក៏ត្រូវស្រាយបញ្ហាចំបងរបស់រឿង អោយបានច្បាស់លាស់សិនដែរ មុននឹងបញ្ចប់ ។

ប្រការសំខាន់ក្នុងការសរសេរវគ្គបញ្ចប់រឿង គឺ**បញ្ចប់ដោយហេតុការណ៍ដែលមិនអាចចៀសវាងបាន ប៉ាន់ស្មានមិនបាន**។ មានន័យថា ពេលអ្នកអានមកដល់វគ្គបញ្ចប់នៃរឿង អ្នកអានត្រូវអានកថាខណ្ឌចុងក្រោយ អានល្បះចុងក្រោយ ហើយទទួលអារម្មណ៍ថាពេញចិត្ត សមនឹងចិត្ត នេះគឺជាផ្លូវតែមួយ... អ្នកអានមិនបានដឹងពីមុនមកឡើយថាអ្វីនឹងកើតឡើង ។ ថ្វីបើវគ្គបញ្ចប់របស់រឿងខ្លះជាអ្វីដែលអាចប៉ាន់ស្មានបាន ដូចជា តួឯកស្រីអាចយកឈ្នះចិត្តតួឯកប្រុស តួអង្គចិត្តអាក្រក់ត្រូវស្លាប់ ។ល។ តែការបញ្ចប់រឿងមិនមែនជាការប្រាប់អោយដឹងថាអ្វីកើតឡើងនោះទេ គឺជាការប្រាប់អោយដឹងថា អ្វីនោះវាកើតឡើងយ៉ាងដូចម្ដេចទៅវិញទេ ។ ទោះជាអ្នកអានអាចកាត់យល់ដឹងថា វគ្គបញ្ចប់នៃរឿងបែបណាក៏ដោយ អ្នកអានក៏នៅតែរង់ចាំមើលថា តើអ្នកនិពន្ធអាចធ្វើអោយគេចំលែកក្នុងចិត្តបានដែររឺទេ?

**ការបញ្ចប់រឿងមានច្រើនបែបដូចជា :**

**ក-ការបញ្ចប់រឿងបែបរីករាយ** (Happy Ending)

អ្នកនិពន្ធខ្លះយល់ឃើញថា បើសិនអ្នកអានយល់ថា អក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងសង្គមនោះ តាមការពិតរបស់ជីវិត គ្រប់យ៉ាងមិនចាំបាច់សប្បាយរីករាយទាំងអស់នោះទេ ។ម្យ៉ាងទៀត ទោះបីជាតួឯកប្រុសនឹងតួឯកស្រីបានសមដូចបំណង

www.elibraryofcambodia.org

ដោយបានរស់នៅរួមគ្នាយ៉ាងមានក្ដីសុខ តែបើអ្នកនិពន្ធនាំអ្នកអានទៅមុខទៀត នោះតួឯកក៏នឹងត្រូវតែស្លាប់។ បើមិនស្លាប់ព្រោះឈឺថ្កាត់ រឺគ្រោះថ្នាក់ផ្សេងៗទេ ក៏គង់តែនឹងស្លាប់ក្នុងវ័យដ៏សមរម្យមួយជាក់ជាមិនខានឡើយ។

ដូចនេះ ការបញ្ចប់រឿងដោយភាពសប្បាយរីករាយ ពុំចាំបាច់ជាការបញ្ចប់យ៉ាងសប្បាយរីករាយនោះទេ គឺវាអាចគ្រាន់តែជាការបញ្ចប់រឿងដោយកើតមានភាពយុត្តិធម៌ ដោយបញ្ហាសំខាន់ត្រូវបានដោះស្រាយ ដោយការប្រយុទ្ធគ្នារវាងតួអង្គនិងតួអង្គត្រូវបានបញ្ចប់ តែតួឯកនៅមានជីវិតរស់នៅឡើយ ក៏គ្រប់គ្រាន់ទៅហើយ។

**ខ-ការបញ្ចប់រឿងបែបនឹកស្មានមិនដល់** (Surprise, Trick Ending)

អ្នកនិពន្ធជាច្រើនបានណែនាំថា យើងមិនគួរប្រើការបញ្ចប់រឿងបែបនឹកស្មានមិនដល់នេះទេ ព្រោះភាគច្រើនវាអាចធ្វើអោយអ្នកអានខកចិត្តណាស់ ដោយគេខំតាមដានរឿងមកយូរហើយ។

ថ្វីបើការបញ្ចប់រឿងបែបនឹកស្មានមិនដល់អាចនឹងធ្វើអោយអ្នកអានមានអារម្មណ៍ចំលែកក្នុងចិត្តក៏ពិតមែន តែបើយើងធ្វើការវិភាគអោយល្អ ក៏នឹងឃើញថា អ្នកអានអាចទទួលអារម្មណ៍ថាគេត្រូវបានបោកបញ្ឆោតអោយធ្លាក់ក្នុងកលឧបាយរបស់អ្នកនិពន្ធទៅវិញ។

**គ-ការបញ្ចប់បែបរង្វង់**(Circular Ending)

ការបញ្ចប់រឿងបែបរង្វង់ សំដៅដល់វគ្គបញ្ចប់នៃរឿងស្រដៀងរឺក៏ដូចគ្នានឹងពេលផ្ដើមរឿងដែរ។ កាលពេលផ្ដើមរឿងអ្នកនិពន្ធបានផ្ដោតលើទីអោយ ដូចជា

www.elibraryofcambodia.org

តួអង្គណាមួយ បញ្ហាសំខាន់ណាមួយ រឺហេតុការណ៍ណាមួយ លុះដល់វគ្គបញ្ចប់ទើបនាំយកគ្រប់ហេតុការណ៍ផ្សេងៗ ឆ្ពោះមករកអ្វីដែលបានផ្តោតលើកាលពីពេលផ្តើមរឿងនោះវិញម្តងទៀត ។

ការបញ្ចប់រឿងបែបនេះយើងចាំបាច់ត្រូវសរសេរអោយពេលផ្តើមរឿងនិងពេលបញ្ចប់រឿងមានការទាក់ទងគ្នា ។ បើមិនដូច្នោះទេ ការបញ្ចប់រឿងមិនអាចនឹងធ្វើអោយអ្នកអានជ្រួតជ្រាបនិងពេញចិត្តបានទេ ។ ប្រការសំខាន់គឺតួឯកត្រូវជួបនឹងបទពិសោធដែលអាចធ្វើតួឯកមានការប្រែប្រួល ត្រូវជួបនឹងហេតុការណ៍ ត្រូវជួបនឹងបញ្ហារឺទំនាស់ ត្រូវមានការតស៊ូអំនត់និងការព្យាយាម រឺអ្វីៗផ្សេងៗទៀតដែលវាអាចនឹងធ្វើអោយវគ្គបញ្ចប់មានគុណតំលៃគ្រប់គ្រាន់ ដើម្បីអាចធ្វើការប្រៀបធៀបគ្នាជាមួយនឹងវគ្គផ្តើមរឿង ។

### ឃ.ការបញ្ចប់បែបមិនចប់ (No Ending)

ប្រលោមលោកដែល "មិនចប់" វាច្រើនតែកើតឡើងដោយសារតែអ្នកនិពន្ធមានការរារែកចិត្ត ផ្លាស់ប្តូរគំនិត ផ្លាស់ប្តូរទិសដៅរបស់រឿងក្នុងពេលដែលបានសរសេរទៅហើយ ។ ថ្វីបើវិធីសរសេរបែបនេះអាចបង្កើតប្រលោមលោកដែលល្អៗបានក៏ដោយ តែវាក៏អាចបង្កើតប្រលោមលោកដែល "**បញ្ចប់បែបមិនចប់**" បានដែរ ។ ប្រលោមលោកខ្លះអ្នកនិពន្ធរកកន្លែងបញ្ចប់រឿងមិនបាន គេក៏ទុកចោលមួយរយៈសិន ។ ប៉ុន្តែលុះដល់ថ្ងៃណាមួយគេអាចនឹកឃើញ រកវគ្គបញ្ចប់ដែលល្អៗបានគេក៏យកវាមកសរសេរបន្តទៀត ។

ប្រលោមលោកដែលចប់តែហាក់ដូចជាមិនចប់អាចបណ្តាលមកពីរឿងនោះ

www.elibraryofcambodia.org

គ្មានចំនុចកំពូលនៃទំនាស់(Climax)ដែលមានថាមពលខ្លាំងបំផុតក្នុងការតំណាល រឿងតាំងពីដើមរឿងរៀងមក ។ ប៉ុន្តែក៏មានអ្នកនិពន្ធខ្លះបានអះអាងថា ការសរសេរវគ្គបញ្ចប់រឿងបែបមិនចប់នេះ គឺជាសិល្បៈម្យ៉ាង ដែលទុកឱកាសអោយអ្នកអានគិតស្រមើស្រមៃដោយខ្លួនឯងល្អជាជាង មិនចាំបាច់មានចំនុចកំពូលនៃទំនាស់ក៏បាន ។

**ង.ការបញ្ចប់ដោយសោកនាកម្ម (Tragedy Ending )**

ប្រលោមលោកដែលបញ្ចប់ដោយសោកនាដកម្មភាគច្រើនអាចធ្វើអោយអ្នកអានចងចាំរឿងបានយូរ ។ ប៉ុន្តែការបញ្ចប់រឿងបែបនេះមិនងាយនឹងសរសេរទេ បើសិនជាយើងចង់អោយរឿងរបស់យើងដក់ជាប់ក្នុងចិត្តរបស់អ្នកអានបានយូរ ដោយអ្នកអានមិនខឹងនឹងអ្នកនិពន្ធនោះ ព្រោះភាពមិនសមប្រាថ្នារបស់តួឯក រឺក៏មរណភាពរបស់តួឯកតែម្យ៉ាងនោះ វាមិនអាចនឹងធ្វើអោយអ្នកអានពេញចិត្តបានទេ ។ លុះណាតែយើងចេះបង្កើតហេតុផលនិងមានបទសរុបដែលសមហេតុសមផលបំផុត និងជាហេតុការណ៍ដែលមិនអាចនឹងជៀសវាងបានផង ទើបអាចនឹងធ្វើអោយអ្នកអានអាចទទួលយកបាន ។

**ការបញ្ចប់រឿងគឺជាការចាប់ផ្តើមជាថ្មី**

ការសរសេររឿងមួយរហូតដល់ចប់គឺជាការបង្កើតស្នាដៃរបស់អ្នក ។ ប៉ុន្តែមនុស្សជាច្រើនបានត្រឹមតែសុបិនរឺបានតែនិយាយ តែមិនដែលធ្វើបានសំរេចសោះ ។ ដូចនេះទោះជាអ្នកសរសេរដើម្បីអ្វី អ្នកចង់បានអ្វី អ្នកក៏បានសរសេរចប់ទៅហើយ ហើយអ្នកអាចនឹងចាប់ផ្តើមសរសេររឿងបន្តទៅទៀត អោយដូចជាបុព្វអ្នកនិពន្ធជំនាន់មុន ដែលលោកបានបន្សល់ស្នាដៃទុករហូតមកដល់សព្វថ្ងៃនេះដែរ ។

www.elibraryofcambodia.org

**សូមជូនរឿងខ្លី**

## រឿង ទឿនចៅកែមែថ្នារ

និពន្ធដោយ **ច័ន្ទ ឫទ្ធិ**

ពេលរសៀលនោះព្រះអាទិត្យរះខ្ពស់សន្ធឹមមើលទៅហាក់ដូចជាខំរត់គេចចេញអោយផុតពីចំហាយកំដៅរបស់ខ្លួនឯងអញ្ចឹង។ នៅឯលើផ្ទះ ក្បែរមាត់បង្អួចមានបុរសម្នាក់អង្គុយសំលឹងមើលទៅបុរសម្នាក់ទៀត ដែលកំពុងដើរសំដៅចូលមកក្នុងចំការ។ បុរសនោះស្លៀកខោជើងវែងពណ៌ខ្មៅ ពាក់អាវដៃវែងពណ៌វាដូចគ្នានឹងខោដែរ ពាក់មួកស្លឹកត្នោត និងមានក្រវ៉ាត់ក្រមានៅចង្កេះផង។ ពេលដើរមកដល់គេឈរច្រត់ចង្កេះ ក្រោមកំដៅថ្ងៃខាងមុខផ្ទះ ហើយស្រែកថាៈ

-"នែ៎ចាប!... ចៅកែប្រាប់អោយខ្ញុំមកដេញឯង ចេញពីចំការនេះ។"

-"ចៅកែក៏បានប្រាប់គ្នាដែរ ណ៎ា**សេក**!... ថាអោយគ្នាមើលថែដីចំការនេះអោយដូចជាជីវិតអញ្ចឹង។"

-"តែ!... ចៅកែឯងនៅអំពេញឯណោះ ឯងមានអីទីពឹងទៅ?... ចៅកែផ្ដាំដាច់ខាតថា បើមានយើង គឺគ្មានឯង។" **សេក**និយាយបណ្ដើរ យកដៃទាំងពីរទាញរឹតជាយក្រមាបណ្ដើរ ព្រមទាំងពើងទ្រូងឡើងបន្តិចផង។

-"ឯងតែម្នាក់ឯងទើរ?..." **ចាប**សួរបញ្ជាក់។

**សេក**សើចហាស់ៗ ញញោកមុខបន្តិច យកជើងកៀសដី បន្ទាប់មកងើយមុខឡើង រួចទើបឆ្លើយតបទៅវិញថា : -" ចុះឯង មានគ្នាប៉ុន្មាននាក់ដែរ?"

-"ម្នាក់ឯង!..." **ចាប**ឆ្លើយ។

www.elibraryofcambodia.org

-"គ្នាក៏ជាកូនប្រុសដែរតើ!..."(**សេក**អះអាង) - "តាមពិតមានគ្នាច្រើន នាក់ តែគ្នាមិនអោយពួកគេមកទេ ឯងកុំបារម្ភអី!..."

"ល្អ!..." **ចាប**ឆ្លើយព្រមទាំងក្រោកឡើងឈរ រួចដើរមកមាត់ទ្វារបង្អាញ រូបរាងខ្ពស់ខ្ពស់ មាឌមាំ ស្មាទូលាយ រួចសួរបន្តថា -"ឯងចង់ប្រើកាំភ្លើងរឺដាវ?"

-"ដាវ!... វាគ្មានសំឡេងរំខានអ្នកដទៃ..."

**ចាប**នៅស្ងៀមមួយសន្ទុះ រួចសើចហាំស១ ហើយទើបសួរថា :

-"ឯងសំលាប់មនុស្ស មិនខ្លាចជាប់គុកទេរឺ?"

-"វាជារឿងរបស់ថៅកែ!...ស្រុកកំពុងតែកើតសង្គ្រាមអញ្ចឹង...វាគ្មានអី គួរអោយបារម្ភនោះទេ ស្រេចលើថៅកែដោះស្រាយទៅចុះ!... យប់នេះជិតភ្លឺ គ្នានឹងមកម្តងទៀត គ្នាទៅសិនហើយណាំ!..."

**ចាប**ងក់ក្បាលជាសញ្ញា បញ្ជាក់ថាយល់ព្រម ។

ពេលនេះបុគ្គលិកលក្ខណៈធម្មជាតិរបស់**សេក** ហាក់ដូចជាវិលត្រលប់មក ដូចដើមវិញ ។ គេដើរបង់បោយចេញតាមទ្វាររបងចំការឆ្ពោះទៅផ្លូវ ដែលមើលទៅ ហាក់ដូចជាគេដើរគយគន់មើលចំការលេងអញ្ចឹង ។

ចំនែក**ចាប** ក៏អង្គុយចុះ ហើយលូកយកបញ្ចប់ថ្នាំខ្លាំងពី[illegible] ទាញយកស្លឹកសង្កែនិងថ្នាំជក់មកមូរបារី រួចកេះដែកកេះ អុជបារី ហើ[illegible] ផ្សែងហុយទ្រលោម អណ្តែតប៉េលប៉ាល មើលទៅហាក់ដូចជាអែអង់ [illegible] រំលែកក្តីកង្វល់របស់ម្ចាស់ដង្ហើមឡើយ ។

www.elibraryofcambodia.org

ស្គាល់គ្នា បានរាប់អានគ្នាជាមិត្ត តាំងពីពេលដែលថៅកែមិនទាន់បែកបាក់គ្នា ពេលថៅកែមានផលប្រយោជន៍រួមគ្នា ។ ប៉ុន្តែព្រហ្មលិខិតហាក់ដូចជាកំនត់អោយជីវិតគេទាំងពីរនាក់ជារបស់ថៅកែរៀង១ខ្លួន ហើយអ្វី១គ្រប់យ៉ាងថៅកែជាអ្នកផ្តល់អោយនិងជាអ្នកបង្កើតឡើង ។

**ចាប** ស្រលាញ់ថៅកែរបស់ខ្លួនជាងជីវិតទៅទៀតហើយគេជឿថា **សេក**ក៏ស្រលាញ់ថៅកែរបស់គេដែរ ។ គេយល់ថា គេត្រូវតែគិតថៅកែជាមុន មុននឹងគិតពីខ្លួនឯង មុននឹងគិតពីកូននិងប្រពន្ធ ។

មនុស្សល្ងិតល្ងង់ដូច**ចាប**មិនអាចដឹងបានថាតើមកពីហេតុអ្វីបានជាថៅកែទាំងពីរ ដែលមានពូជអំបូរតែមួយ បែរជាប្រេះឆា បែកបាក់គ្នា ក្លាយជាអ្នកដទៃអញ្ចឹងទៅវិញ ។ គេគ្រាន់តែដឹងថា **ថៅកែបង**បានបោះបង់ចោលការងារចំការ នាំក្រុមគ្រួសារទៅនៅឯភ្នំពេញតាំងតែពីចុងឆ្នាំ ១៩៧១ មកម្លេះ ។

លុះពាក់កណ្តាលអធ្រាតចូលមកដល់ **សេក**ដើរចេញមករឿយ១ រហូតផុតរបងចំការដោយដួងចិត្តអួលអាក់ តែ**សេក**នៅតែដើរទៅមុខទាំងបង្ខំចិត្ត ។ ខណៈនោះគេនឹកស្រមៃឃើញរឿងដែលម្តាយគេធ្លាប់បាននិយាយប្រាប់ កាលពីនៅជំទង់ជាច្រើនរឿង ទាក់ទងនឹងគុណបំណាច់របស់ខ្មោចឪពុកថៅកែមកលើឪពុកគេ ។

ថៅកែបែកបាក់គ្នាព្រោះរឿងអ្វីអ្នកបំរើដូច**សេក**ពុំមានសមត្ថភាពអាចនឹងលបលួចយល់ដឹងបានឡើយ ។ គេបានត្រឹមតែដឹងពីតួនាទីនិងភាពជាកូនប្រុសដែលគេបាននិងកំពុងប្រគល់ជូនថៅកែតែម្នាក់គត់ប៉ុណ្ណោះ ។

-"**ចាប**អើយ!...ឯងគួរតែចាកចេញអោយឆ្ងាយទៅ..."**សេក**គិតក្នុងចិត្ត

www.elibraryofcambodia.org

ទោះជាដឹងថាគ្មានថ្ងៃដែលអាចនឹងកើតឡើងបាន ដ្បិតចាបគឺជាកូនប្រុសដែលមិន ព្រមបោះបង់តួនាទី មិនប្រឆាំងបញ្ជា មិនបែរខ្នងដាក់ចៅកែ ដូចគ្នានឹងខ្លួនគេដែរ ។

**សេក**ងើយមើលព្រះចន្ទពេញបូណ៌មី ដែលមើលទៅហាក់ដូចជាកំពុងតែ ជួយបំភ្លឺផ្លូវអោយគេ ។ នរណាឈ្នះ នរណាចាញ់ គេមិនទាន់បានគិតនៅឡើយទេ វាជារឿងរបស់ពេលវេលានិងព្រហ្មលិខិត ។ គេគិតថាចាបក៏នៅមិនទាន់បានគិត រឿងនេះដូចគេដែរ ។

កាន់តែគិតកាន់តែទទួលអារម្មណ៍ថាស្មុគស្មាញ... **សេក**គ្រវីក្បាល រួចដើរ ត្រុយទៅខាងមុខ ។ ដើរបណ្ដើរគិតបណ្ដើរមិនយូរប៉ុន្មាន**សេក**ក៏ដើរចូលទៅដល់ក្នុង បរិវេណចំការ ដែលមាន**ចាប**កំពុងឈររង់ចាំស្រាប់ហើយ ។

មួយសន្ទុះក្រោយមកក៏លាន់លឺសំឡេងផ្លែដាវប៉ះទង្គិចគ្នា រួមនឹងសំឡេង ហត់ដង្ហក់របស់អ្នកទាំងពីរ លាន់លឺដូចបីសាចស្រេកឈាម គួរអោយព្រឺខ្លាច ។

លុះសំលេងនោះស្ងាត់បាត់ទៅ ដូងចន្ទបាំងជួរព្រៃឯនាយចំការ លាន់ រំពងដោយសំឡេងមាន់រងាវខ្សៀវខ្សារ នាពេលទៀបភ្លឺ ។ **សេក**ឈរទ្រេតទ្រោតនៅ ក្បែរដើមខ្នុរ ស្ដាប់សំឡេងមាន់រងាវលឺល្វើយៗ ដ្បិតគេអស់កំលាំងស្រវាំងភ្នែក មើលអ្វីមិនច្បាស់ ។ ចំនែក**ចាប**ដេកស្ដូកស្ដឹងតែម្នាក់ឯង ឯក្បែរគល់ស្វាយ ។

**សេក**អង្គុយនៅក្បែរដើមខ្នុរ កែវភ្នែកសំលឹងមើលទៅសាកសពរបស់**ចាប** ទាំងក្រៀមក្រំ ។ ចំនែកក្រម៉ាក្រវ៉ាត់ចង្កេះនិងខោរបស់គេពោរពេញទៅដោយស្នាម ដំណក់ឈាម ដែលហូរស្រក់ពីមុខរបួសលើផ្ទៃមុខ ដើមទ្រូង ដែលគ្មានពាក់អាវ ។ តាមស្នាកស្នាមរបួសនៅមានឈាមពណ៌ក្រហមជ្រាបចេញរិញៗមិនដាច់រយៈ ។

www.elibraryofcambodia.org

ខ្ទុយស្របក់ក្រោយអក **សោក**ក្រោកឡើង ដើរយឺតៗទៅជិត**ចាប** ហើយ អង្គុយចុះផ្ដេកខ្លួនថ្នមៗទន្ទឹមនឹងសាកសពរបស់**ចាប** ។ ពេលនោះពន្លឺព្រះចន្ទកាន់តែ ខ្សោយទៅៗ ដោយចុះចាញ់អំនាចនៃពន្លឺរបស់ព្រះអាទិត្យ ដែលកាន់តែភ្លឺច្បាស់ ឡើងបន្តិចម្ដងៗ នៅពេលព្រឹកព្រលឹមស្រាងៗ ។

ទោះជាយ៉ាងណាក្ដី**សោក**នៅតែជឿជាក់ថាមិត្តភាពរវាងគេនិង**ចាប**គ្មានថ្ងៃ បញ្ចប់ទេ តែអ្វីដែលបានបាត់បង់ទៅគឺជីវិតរបស់មិត្តទេតើ ។ ចំណែកឯក្ដីស្រលាញ់ និងមិត្តភាពនៅតែមាន... សូម្បីតែពេលនេះ ក៏នៅតែមានដែរ ។

ពេលនេះគេទទួលអារម្មណ៍ថាទឹកភ្នែករបស់ខ្លួនលាយឡំជាមួយញើសនិង ឈាមកំពុងហូរស្រោចលើផែនថ្កាល់ទាំងគូ ។ **សោក**មិនគ្រាន់តែមានអារម្មណ៍ថាខ្លួន កំពុងតែបាត់បង់ឈាម ដែលកំពុងហូរវិញៗ ចេញពីរាងកាយតែប៉ុណ្ណោះទេ គឺវា ថែមទាំងបាត់បង់កូន បាត់បង់ប្រពន្ធ និងបានបាត់បង់មិត្តរួចទៅហើយ ។ ជាពិសេស គេក៏កំពុងតែនឹងបាត់បង់ថៅកែដែរ តែគេមិនបានទទួលអារម្មណ៍ថាឈឺចាប់ ដូច បាត់បង់មិត្ត កូន និងប្រពន្ធនោះទេ ។ ផ្ទុយទៅវិញគេសប្បាយចិត្តទៅវិញទេ ចំពោះ ការបាត់បង់ថៅកែក្នុងពេលនេះ ។

**រឿងថៅកែម៉ែផ្ដាំ**រសាត់ចូលមកក្នុងគំនិតរបស់**សោក**ម្ដងទៀត...ជារឿងរ៉ាវ ដែលម្ដាយគេធ្លាប់បានតំណាល បានផ្ដែផ្ដាំដដែលៗជាច្រើនលើកច្រើនសា ថាអោយ គេចងចាំជានិច្ច ។ **សោក**ឃើញស្រមោលម្ដាយដែលបានលាចាកលោកទៅយូរហើយ ស្អុងៗ ព្រមជាមួយនឹងរឿងថៅកែដែលម៉ែបានផ្ដាំទាំងនោះ ។

-"ម៉ែ!... បណ្ដាំរបស់ម៉ែត្រឹមត្រូវ... ល្អណាស់... តែខ្ញុំគិតថា...ស្ទើរៗ!"

www.elibraryofcambodia.org

**សេក**គិតរួចថ្ងូរព្រោះឈឺចាប់នឹងស្នាមរបួសដែលមានស្ទើរតែពាសពេញរាងកាយ ។

-"ម៉ែ!... កូនយល់ថាសំណាងល្អណាស់ដែលកូនមិនទាន់បាននិយាយរឿងទាំងនោះអោយចៅប្រុសរបស់ម៉ែស្តាប់... រឿងរ៉ាវដ៏សែនឈឺចាប់ដូចរូបខ្ញុំក្នុងពេលនេះ ។ **សេក**និយាយតិចៗដោយមានស្នាមញញឹមអបអរនឹងជោគជ័យដែលគេបានបំពេញជូនចៅកែ ។

**សេក**មិនដែលនឹកជឿសោះឡើយថាអំនាចនៃភក្តីភាពអាចរុញច្រានញែកបំបែកមិត្តភាពដ៏ល្អបាន ។ ទោះជាពេលនេះតែមានអារម្មណ៍ថាភារៈកិច្ចទាំងឡាយដែលគេត្រូវធ្វើកំពុងតែនឹងត្រូវបានបញ្ចប់ក្នុងពេលដ៏ខ្លីបន្តិចទៀតនេះក្តី តែមិត្តភាពរវាងគេនិង**ចាប**នឹងស្ថិតនៅជាអមតៈ ។

ដៃទាំងពីររបស់**សេក**ឱបសព**ចាប**យ៉ាងណែន មុននឹងដង្ហើមចុងក្រោយធ្វើដំនើរចាកចេញពីរាងកាយរបស់គេទៅ បន្សល់ទុកនូវសេរីភាព រួចដុតពីភារៈពាក់ព័ន្ធទាំងឡាយទាំងពួង ហើយក៏ពុំមានអ្វីមកបង្ខំចិត្តនិងគ្មាននរណាធ្វើជាចៅកែរបស់គេ តទៅទៀតឡើយ ។

**ចប់**

**ប្រសិនបើអ្នកជាអ្នកនិពន្ធរឿងរឿងចៅកែម៉ែថ្កាំ តើអ្នកនឹងបញ្ចប់រឿងយ៉ាងដូចម្តេចវិញ?**

17 DEC 2009

www.elibraryofcambodia.org




www.elibraryofcambodia.org